ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

ភាសាខ្មែរ

ថ្នាក់ឆ្នាំទី ១



សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

គណិតវិទ្យា

ថ្នាក់ឆ្នាំទី ១

ឯកសារសម្រាប់គ្រូ

បោះពុម្ពលើកទី២

ឆ្នាំ ២០១៥

គណៈកម្មការត្រួតត្រង

ឯកឧត្តម ណាត ប៊ុនរឿន	លោក អ៊ុក សុវណ្ណ
ឯកឧត្តម អ៊ឹម កុច	លោក ចាន់ សុភា
ឯកឧត្តម សំ សេរីរតន៍	លោក ជា វណ្ណេត

គណៈកម្មការនិពន្ធ

លោកស្រី ទូច សុភាព	លោកស្រី ឡាច សុម៉ាលី
លោកស្រី សាន ណាវ៉ា	លោកស្រី អៃ ចាន់ម៉ាលី
លោកស្រី ជឹម យ៉ាធីតា	លោកស្រី ពៅ រដ្ឋា

អ្នករៀបរៀងនិងរចនាចំណែរ

លោកស្រី ខ្វង់ គឹមទូច	លោក អាន រ៉ូប្រាវ

គណៈកម្មការត្រួតពិនិត្យ

លោក ជា វណ្ណេត	លោកស្រី មិន វិចិត្រា
លោក អាន រ៉ូប្រាវ	លោកស្រី ជុំ វណ្ណា
លោកស្រី ហ៊ុន សុជាតិ	លោកស្រី ឡាច សុខេម៉ា
លោកស្រី ខ្វង់ គឹមទូច	

បញ្ជីអត្ថបទ

អារម្ភកថា ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ២
ផ្នែកទី២៖ អត្ថបទស្តាប់ ៨
ផ្នែកទី៣៖ លំនាំនៃការបង្រៀន ១៧
ផ្នែកទី៤៖ សលាកប័ត្រជំពូកនិងមេរៀន ៣១
ជំពូកទី១ : ព្យញ្ជនៈពួក «អ» ៣២
ជំពូកទី២ : ព្យញ្ជនៈពួក «អ៊» ៣៩
ជំពូកទី៣ : ង៉ ញ៉ ប៉ ម៉ យ៉ រ៉ ល៉ ប៊ ស៊ ហ៊ អ៊ ៤៥
ជំពូកទី៤ : ប្រកបនឹង ក ក់ ង ង់ ច ច់ ញ ញ់ ត ត់ ន ន់ ៤៨
ជំពូកទី៥ : ព្យញ្ជនៈផ្ញើជើង ៥៨
ជំពូកទី៦ : ព្យាង្គតម្រួត ៧២
ជំពូកទី៧ : បវេសនកាល ៧៧
ជំពូកទី៨ : ថ្នាក់រៀនខ្ញុំ ៧៩
ជំពូកទី៩ : ប្រដាប់ប្រដាសិក្សា ៨៣
ជំពូកទី១០ : គ្រួសារខ្ញុំ ៨៦
ជំពូកទី១១ : ការងារឪពុកម្តាយខ្ញុំ ៨៨
ជំពូកទី១២ : យើងរៀន យើងលេង ៩១
ជំពូកទី១៣ : ទិដ្ឋភាពនៅភូមិខ្ញុំ ៩៣
ជំពូកទី១៤ : ផ្ទះខ្ញុំ ៩៥
ជំពូកទី១៥ : ផ្សារនៅភូមិខ្ញុំ ៩៧
ជំពូកទី១៦ : ពិធីបុណ្យនៅភូមិខ្ញុំ ១០០

អារម្ភកថា

ឯកសារជំនួយគ្រូមុខវិជ្ជាភាសាខ្មែរថ្នាក់ឆ្នាំទី១ នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង ក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការដើម្បីភាពញញឹមនៃកុមារ នៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សាសម្រាប់សាលាបឋមសិក្សា។ ឯកសារនេះត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សានៅអង្គការដើម្បីភាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងសម្រួលដល់ការបង្រៀនមុខវិជ្ជាភាសាខ្មែរថ្នាក់ឆ្នាំទី១ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះ មានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សានៅសាលាបឋមសិក្សា លំនាំនៃការបង្រៀនតាមសមត្ថភាពនីមួយៗ និងសលាកប័ត្រជំពូកនិងមេរៀន ពិសេសផ្តោតទៅលើចម្លើយរបស់សំណួរ និងកំណែលំហាត់ដែលផ្តល់នូវភាពងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូ ក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើងមិនទាមទារឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់គឺ ជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធ ក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យសព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសរសេរ ឬសំណួរផ្ទាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូភាសាខ្មែរថ្នាក់ឆ្នាំទី១ នេះនឹងបានជាប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការនិពន្ធ

ផ្នែកទី១
បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សាមុខវិជ្ជា ភាសាខ្មែរថ្នាក់ឆ្នាំទី១ នេះ គឺជាការសំយោគបញ្ចូលគ្នារវាងកម្មវិធីសិក្សា មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ទី១និងថ្នាក់ទី២ នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជាភាសាខ្មែរ ថ្នាក់ឆ្នាំទី១នេះ មានចំនួន១៣ម៉ោងសិក្សាក្នុង១សប្តាហ៍ ដែល១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

ជំពូក	មេរៀន	ប្រភេទមេរៀន	ចំណងជើងមេរៀន	រយៈពេល
ទី០៖	១	អាននិងសរសេរ	ស្រៈនិស្ស័យ	៤ម៉
ស្រៈនិងព្យញ្ជនៈ	២	អាន	ព្យញ្ជនៈ៣៣តួ	២ម៉
ទី១៖	១	ស្តាប់	ចម្រៀងអក្ខរក្រម	២ម៉
ព្យញ្ជនៈពួក"អ"	២	អាននិងសរសេរ	ព្យញ្ជនៈ "ក ត"	២ម៉
	៣	អាននិងសរសេរ	ព្យញ្ជនៈ "ច ឆ"	២ម៉
	៤	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉
	៥	និយាយ	ប្រាប់ឈ្មោះ អាយុ ថ្នាក់រៀន និង វត្តនៅក្នុងថ្នាក់	១ម៉
	៦	អាននិងសរសេរ	ព្យញ្ជនៈ "ដ ផ"	២ម៉
	៧	អាននិងសរសេរ	ព្យញ្ជនៈ "ប ថ"	២ម៉
	៨	និយាយ	ការណែនាំមិត្តភក្តិឱ្យស្គាល់គ្នា	១ម៉
	៩	អាននិងសរសេរ	ព្យញ្ជនៈ "ខ"	២ម៉
	១០	ស្តាប់	រឿង រៃនិងស្រមោច	២ម៉
	១១	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉
	១២	និយាយ	សមាជិកគ្រួសារខ្ញុំ	១ម៉
	១៣	អាននិងសរសេរ	ព្យញ្ជនៈ "ប ហ"	២ម៉
	១៤	អាននិងសរសេរ	ព្យញ្ជនៈ "ស ណ"	២ម៉
	១៥	អាននិងសរសេរ	ព្យញ្ជនៈ "ឡ អ"	២ម៉
	១៦	ស្តាប់	មេសូត្រ (បទកាកគតិ)	២ម៉
	១៧	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉
ទី២៖	១	អាននិងសរសេរ	ព្យញ្ជនៈ "គ ភ"	២ម៉
ព្យញ្ជនៈពួក "អ៊"	២	អាននិងសរសេរ	ព្យញ្ជនៈ "ជ ង ធ"	២ម៉
	៣	អាននិងសរសេរ	ព្យញ្ជនៈ "ព ញ"	២ម៉
	៤	ស្តាប់	រឿង ក្អែកមានគំនិត	២ម៉
	៥	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉
	៦	និយាយ	ប្រាប់ព័ត៌មានពីឪពុកម្តាយ ឬ អាណាព្យាបាល	២ម៉
	៧	អាននិងសរសេរ	ព្យញ្ជនៈ "ឃ ឈ យ ល"	២ម៉
	៨	អាននិងសរសេរ	ព្យញ្ជនៈ "ឝ ឍ ទ ន"	២ម៉
	៩	អាននិងសរសេរ	ព្យញ្ជនៈ "ម រ វ"	២ម៉

	១០	វេយ្យាករណ៍	ខ្ញុំ ឯង គេ យើង	១ម៉	
	១១	ស្តាប់	រឿង កូនទន្សាយទៅសាលារៀន	២ម៉	
	១២	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
ទី៣៖ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊	១	និយាយ	ប្រាប់ទីតាំងមនុស្ស សត្វ វត្ថុ និង ទីកន្លែង	២ម៉	
	២	អាននិងសរសេរ	សញ្ញាធ្មេញកណ្តុរឬសញ្ញាមូសិកទន្ត "ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉"	៤ម៉	
	៣	អាននិងសរសេរ	សញ្ញាសក់ ក ឬសញ្ញាត្រីសព្ទ "ប៊ ស៊ ហ៊ អ៊"	២ម៉	
	៤	វេយ្យាករណ៍	របស់ខ្ញុំ របស់ឯង របស់វា របស់យើង របស់គេ	១ម៉	
	៥	ស្តាប់	រឿង ខ្លានិងកេពីរ	២ម៉	
	៦	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
ទី៤៖ ព្យញ្ជនៈប្រកប	១	ស្តាប់	រឿង ទន្សាយចង់ស៊ីចេក	២ម៉	
	២	អាននិងសរសេរ	ប្រកបនឹង □ក □ក់	២ម៉	
	៣	អាននិងសរសេរ	ប្រកបនឹង □ង □ង់	២ម៉	
	៤	អាននិងសរសេរ	ប្រកបនឹង □ច □ច់	២ម៉	
	៥	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
	៦	អាននិងសរសេរ	ប្រកបនឹង □ញ □ញ់	២ម៉	
	៧	អាននិងសរសេរ	ប្រកបនឹង □ត □ត់	២ម៉	
	៨	អាននិងសរសេរ	ប្រកបនឹង □ន □ន់	២ម៉	
	៩	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
	១០	អាននិងសរសេរ	ប្រកបនឹង □ប □ប់	២ម៉	
	១១	អាននិងសរសេរ	ប្រកបនឹង □ម	២ម៉	
	១២	អាននិងសរសេរ	ប្រកបនឹង □យ	២ម៉	
	១៣	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
	១៤	អាននិងសរសេរ	ប្រកបនឹង □ល □ល់	២ម៉	
	១៥	អាននិងសរសេរ	ប្រកបនឹង □វ	២ម៉	
	១៦	អាននិងសរសេរ	ប្រកបនឹង □ស □ស់	២ម៉	
	១៧	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉	
	១៨	ស្តាប់	រឿង ដឹងសងដឹង អំបែងសងអំបែង	២ម៉	
	១៩	អាននិងសរសេរ	ស្រៈពេញតួ ៖ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ	៤ម៉	
ទី៥៖ ព្យញ្ជនៈផ្ញើជើង	១	អាននិងសរសេរ	ព្យញ្ជនៈនិងជើងព្យញ្ជនៈ	២ម៉	
	២	អាននិងសរសេរ	ក្ត ក្ប ក្រ ក្ល ក្ស ក្ត ក្ង ក្ន ក្ម	៤ម៉	

	៣	អាននិងសរសេរ	ខ្ ខ្ត ខ្ន ខ្ប ខ្ព ខ្យ ខ្ល ខ្ឃ ខ្យ ខ្ញ ខ្ម	៤ម៉ោ
	៤	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉ោ
	៥	អាននិងសរសេរ	គ្រ ត្ន ត្ម ឃ្ល ឃ្ម ឃ្ន ឃ្ម	៤ម៉ោ
	៦	អាននិងសរសេរ	ច្ឆ ច្រ ច្ច ឆ្ក ឆ្ត ឆ្ព ឆ្ព ឆ្ល ឆ្ង ឆ្ញ ឆ្ង ឆ្ន ឆ្ម	៤ម៉ោ
	៧	អាននិងសរសេរ	រៀនសាឡើងវិញ	៦ម៉ោ
	៨	អាននិងសរសេរ	ជ្រ ជ្ង ឈ្ង ឈ្ន ឈ្ម ឈ្ល	៤ម៉ោ
	៩	វេយ្យាករណ៍	សញ្ញាសួរ(?) សញ្ញាខណ្ឌ (។) និងសញ្ញាឧទាន (!)	១ម៉ោ
	១០	អាននិងសរសេរ	ប្ត ប្រ ប្ល ប្ព	២ម៉ោ
	១១	អាននិងសរសេរ	ផ្ក ផ្ត ផ្ង ផ្ង ផ្ត ផ្ង ផ្ន ផ្ល ផ្ស ផ្ម	៤ម៉ោ
	១២	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉ោ
	១៣	អាននិងសរសេរ	ព្ន ព្រ ព្យ ភ្ញ ភ្ន ភ្ន ភ្ល	៤ម៉ោ
	១៤	អាននិងសរសេរ	ម្ក ម្ង ម្ង ម្ត ម្ង ម្ន ម្ង ម្ន ម្ព ម្យ ម្រ ម្ល ម្ស ម្ម ម្ព	៦ម៉ោ
	១៥	អាននិងសរសេរ	រៀនសាឡើងវិញ	៦ម៉ោ
	១៦	អាននិងសរសេរ	ត្ក ត្ប ត្ម ត្រ ត្ល ត្ព	៤ម៉ោ
	១៧	អាននិងសរសេរ	ថ្ក ថ្ត ថ្ង ថ្ន ថ្ព ថ្ម ថ្ល ថ្ង	៤ម៉ោ
	១៨	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉ោ
	១៩	អាននិងសរសេរ	ទ្រ ទ្ង ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្ង	៤ម៉ោ
	២០	អាននិងសរសេរ	ល្ង ល្ង ល្ប ល្ត ល្ម ល្ង ល្ត ល្ព ហ្គ ហ្ង	៥ម៉ោ
	២១	អាននិងសរសេរ	រៀនសាឡើងវិញ	៦ម៉ោ
	២២	អាននិងសរសេរ	ស្ក ស្ត ស្ង ស្ន ស្ង ស្ត ស្ត ស្ន ស្ប ស្ត ស្ម ស្ល ស្រ ស្ង ស្ព	៦ម៉ោ
	២៣	ស្តាប់	រឿង ទន្សាយរត់ប្រណាំងជាមួយអណ្តើក	២ម៉ោ
	២៤	អាននិងសរសេរ	រៀនសាឡើងវិញព្យញ្ជនៈដែលមានសូរដូចគ្នា	២ម៉ោ
ទី៦ៈ ព្យាង្គតម្រួត	១	អាននិងសរសេរ	ង្ក ង្ង ង្ត ង្ប ង្ង ង្រ ង្ង ង្ស ង្ត ង្ព	៤ម៉ោ
	២	អាននិងសរសេរ	ញ្ច ញ្ជ ញ្ជ ញ្ឈ ញ្ញ	៤ម៉ោ
	៣	អាននិងសរសេរ	រៀនសាឡើងវិញ	២ម៉ោ
	៤	អាននិងសរសេរ	ណ្ក ណ្ឃ ន្ត ន្ថ ន្ទ ន្ទ ន្ន ន្ស	៤ម៉ោ
	៥	អាននិងសរសេរ	ម្ប ម្ព ម្ភ ម្ម ម្រ ម្ល	៤ម៉ោ
	៦	អាននិងសរសេរ	ង្ក្រ ង្ក្រ ញ្ច្រ ញ្ជ្រ ន្ត្រ ន្ទ្រ	២ម៉ោ
	៧	អាននិងសរសេរ	រៀនសាឡើងវិញ	៤ម៉ោ
	៨	អំណាន	រឿង ព្រះអាទិត្យនិងព្រះពាយ	២ម៉ោ
	៩	អំណាន	សាលារៀន	២ម៉ោ

ទី៧៖ បវេសនកាល	១	ស្តាប់	រឿង កូនខ្លាឃ្មុំដ៏ក្លាហាន	២ម៉ោ
	២	អំណាន	ថ្ងៃចូលរៀនដំបូងនៃឆ្នាំសិក្សាថ្មី	២ម៉ោ
	៣	អំណាន	មេសូត្រ ៖ រីករាយថ្ងៃចូលរៀន	២ម៉ោ
ទី៨៖ ថ្នាក់រៀនខ្ញុំ	១	ស្តាប់	រឿង ទម្លាប់ថ្មីរបស់ខ្ញុំ	២ម៉ោ
	២	វេយ្យាករណ៍	ពាក្យបង្ហាញមនុស្ស សត្វ វត្ថុ និងរុក្ខជាតិ	២ម៉ោ
	៣	អំណាន	ថ្នាក់រៀនខ្ញុំ	២ម៉ោ
	៤	វេយ្យាករណ៍	ពាក្យសម្រាប់សម្គាល់ទីតាំងអ្វីមួយ	២ម៉ោ
	៥	សំណេរ	ពណ៌នាថ្នាក់រៀន	២ម៉ោ
ទី៩៖ ប្រដាប់ប្រដាសិក្សា	១	និយាយ	សកម្មភាពខ្ញុំនៅសាលារៀន	២ម៉ោ
	២	អំណាន	មេសូត្រ៖ ប្រដាប់ប្រដាសិក្សារបស់ខ្ញុំ(បទកាកគតិ)	២ម៉ោ
	៣	អំណាន	រឿង មិត្តល្អរបស់កូនខ្លាឃ្មុំទូទូ	២ម៉ោ
	៤	សំណេរ	ពណ៌នាសកម្មភាពក្នុងថ្នាក់រៀន	២ម៉ោ
ទី១០៖ គ្រួសារខ្ញុំ	១	ស្តាប់	រឿង ក្មេងគង្វាលចៀម	២ម៉ោ
	២	វេយ្យាករណ៍	ពាក្យបង្ហាញសកម្មភាព	២ម៉ោ
	៣	អំណាន	រឿង កូនទន្សាយទីណូ	២ម៉ោ
ទី១១៖ ការងារឪពុកម្តាយខ្ញុំ	១	វេយ្យាករណ៍	ពាក្យបង្ហាញលក្ខណៈរបស់មនុស្ស សត្វ រុក្ខជាតិ និងវត្ថុ	២ម៉ោ
	២	អំណាន	ចម្រៀង៖ពុកម៉ែខ្ញុំ(លំនាំបទខ្ញុំមានមាត់សម្រាប់និយាយ)	២ម៉ោ
	៣	អំណាន	សិប្បកម្មតម្បាញហូល	២ម៉ោ
	៤	សំណេរ	ពណ៌នាសកម្មភាពជាងដែរ	២ម៉ោ
ទី១២៖ យើងរៀនយើងលេង	១	អំណាន	ពេលចេញលេង	២ម៉ោ
	២	អំណាន	មេសូត្រ៖ ការងារយើងនៅសាលារៀន(បទកាកគតិ)	២ម៉ោ
ទី១៣៖ ទិដ្ឋភាពនៅភូមិខ្ញុំ	១	ស្តាប់	ចម្រៀង៖ សម្រស់ភូមិខ្ញុំ (លំនាំបទជ័យលក់នំបញ្ចុក)	២ម៉ោ
	២	អំណាន	ផ្លូវថ្នល់នៅភូមិខ្ញុំ	២ម៉ោ
	៣	សំណេរ	ពណ៌នាអំពីទិដ្ឋភាពភូមិអ្នកនៅរដូវស្រូវទុំ	២ម៉ោ
ទី១៤៖ ផ្ទះខ្ញុំ	១	អំណាន	ផ្ទះខ្ញុំ	២ម៉ោ
	២	អំណាន	មេសូត្រ៖ ផ្ទះជីតាខ្ញុំ (បទកាកគតិ)	២ម៉ោ
ទី១៥៖ ផ្សារនៅភូមិខ្ញុំ	១	ស្តាប់	រឿង ខ្លែងមួយ	២ម៉ោ
	២	អំណាន	ខ្ញុំទៅផ្សារទំនើប	២ម៉ោ
	៣	អំណាន	មេសូត្រ៖ ផ្សារនៅភូមិខ្ញុំ(បទកាកគតិ)	២ម៉ោ

	៤	សំណេរ	សកម្មភាពពេលដើរផ្សារ	២ម៉	
ទី១៦៖ ពិធីបុណ្យនៅភូមិខ្ញុំ	១	ស្តាប់	រឿង សត្វត្មាត	២ម៉
	២	អំណាន	រឹករាយថ្ងៃបុណ្យចូលឆ្នាំថ្មី	២ម៉
	៣	អំណាន	មេសូត្រ៖ ទៅវត្តសប្បាយ (បទកាកគតិ)	២ម៉
	៤	សំណេរ	ពណ៌នាអំពីវត្តនៅភូមិអ្នក	២ម៉

សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់ ១៣ម៉ × ៣៨សប្តាហ៍ = ៤៩៤ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន ៣១៥ម៉ោងសិក្សា
- សរុបម៉ោងសល់ ១៧៩ម៉ោងសិក្សា

ផ្នែកទី២
អត្ថបទស្តាប់

ជំពូកទី១

ចម្រៀងអក្ខរក្រម

ក ខ យើងត្រូវខិតខំ　　គ គិតរៀបចំទៅសាលារៀន
យ ឃាស្តាប់គ្រូបង្រៀន　　ង ងា កុំអៀន ក ខ គ ឃ ង។

(ក ខ គ ឃ ង : បន្ទរ)

ច ចា រាបសារមទម　　ឆ ឆី សមរម្យ ជ ជួបសំពះ
ឈ ឈប់ធ្វើអ្វីផ្តេសផ្តាស　　ញ ញឹមកុំខ្មាស ច ឆ ជ ឈ ញ។

(ច ឆ ជ ឈ ញ : បន្ទរ)

ដ ប ឋ ឍ ណ និងណា　　ពុកម៉ែត្រេកអរឃើញកូនទៅរៀន
ត តា តាមដំបូន្មាន　　សង្វាតសូត្ររៀន ត ថ ទ ធ ន។

(ត ថ ទ ធ ន : បន្ទរ)

ប ផ ព ភ និងម　　ស្រឡាញ់រាប់រកមិត្តភក្តិគ្រប់គ្នា
យ រ ល វ សាមគ្គា　　ស ហ ឡ អ ជាសាមសិបបីតួ។

(យ រ ល វ ស ហ ឡ អ : បន្ទរ)

(ដកស្រង់ពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

រឿង រនាំងស្រមោច

មានសត្វរមាមួយហើរច្រៀងលេងពេញមួយរដូវប្រាំង។ វាមិនខ្វល់ខ្វាយរកស្បៀងអាហារទុកសម្រាប់ខ្លួនឡើយ។ ឯហ្វូងស្រមោចជាសត្វ ឧស្សាហ៍ព្យាយាមនាំគ្នាជញ្ជូនស្បៀងទុកបង្ការក្រែងខ្វះខាតនៅថ្ងៃមុខ។ នៅរដូវវស្សា មានភ្លៀងធ្លាក់ជោកជាំ រមាមិនបានទៅរកអាហារទេ។ វាអត់អាហារហើយស្រេកឃ្លានយ៉ាងខ្លាំង។ វាក៏ហើរទៅខ្ចីស្បៀងរបស់ស្រមោច ដោយនិយាយថា **មិត្តអើយខ្ញុំឃ្លានណាស់! ពុំមានអ្វីបរិភោគទេ ព្រោះភ្លៀងខ្លាំងពេកមិនអាចរកចំណីបាន។ សូមមិត្តឱ្យខ្ញុំខ្ចី ស្បៀងខ្លះទម្រាំដល់រដូវប្រាំង ខ្ញុំរកសងវិញ។** ស្រមោចឮហើយសួរថា៖**កាលពីរដូវប្រាំង តើមិត្តរមាលធ្វើអ្វីបានជាមិនរកស្បៀងទុក?** រមាឆ្លើយថា **កាលពីរដូវប្រាំង ខ្ញុំរមាលតែសប្បាយច្រៀងលេងលើដើមឈើភ្លេចខ្លួន ទើបមិនបានរកស្បៀងទុក។** ស្រមោចឮហើយឆ្លើយថា **នេះមកពីមិត្តរមាលតែសប្បាយភ្លេចខ្លួន លុះដល់ពេលអត់ឃ្លានទើបរកខ្ចីគេ។ ខ្ញុំមានស្បៀងទុកល្មម តែកូនចៅប៉ុណ្ណោះពុំមានស្បៀងសម្រាប់ចែករំលែកឱ្យមិត្តខ្ចីឡើយ។** រមាទាល់ប្រាជ្ញាអស់សង្ឃឹមក៏ហើរទៅវិញ រស់ដោយវេទនាពេញមួយរដូវវស្សា។

(ដកស្រង់ពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

មេសូត្រ បឧភាវគតិ

ម៉ែដ៏មានគុណ　　គុណលោកសែនធ្ងន់　　គ្មានអ្វីប្រៀបបាន
បីបាច់រក្សា　　កូនបានសុខសាន្ត　　លំបាកប៉ុន្មាន
លោកខំតស៊ូ។

(ដកស្រង់ពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

ជំពូកទី២

រឿង ក្អែកមានគំនិត

មានក្អែកមួយស្រេកទឹកខ្លាំងណាស់ វាហើរស្រែកខ្វកៗ ព្រោះរកទឹកផឹកមិនបាន។ វាបានឃើញក្អមមួយមានទឹកបន្តិច វាមិនអាចផឹកទឹកនោះបាន ព្រោះក្អមនោះមានកវែង។

ក្អែកហើរទៅពាំក្រួសមួយគ្រាប់មកទម្លាក់ក្នុងក្អមនោះ។ ទឹកក្នុងនោះឡើងបន្តិច។ បន្ទាប់មកវាពាំគ្រាប់ក្រួសមកទម្លាក់ក្នុងក្អមទៀត។ វាទម្លាក់ក្រួសយ៉ាងច្រើនក្នុងក្អមនោះ។ ទឹកក៏ឡើងដល់មាត់ក្អម។ ឃើញដូចនេះ ក្អែកក៏ស្រែកឡើង **ខ្ញុំអាចផឹកទឹកបានហើយ!**

(ដកស្រង់ពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី១ បោះពុម្ពឆ្នាំ២០១០)

រឿង កូនឧន្សាយទៅសាលារៀន

ព្រឹកនេះ ទីណូគេងលក់ស្កប់ស្កល់ ទោះបីមានពន្លឺព្រះអាទិត្យចូលតាមបង្អួច សំឡេងសត្វចាបយំចេបៗ! ចេបៗ! ក៏ទីណូនៅតែស្រមុកឃូៗ។ មួយរំពេចនោះ នាឡិការោទ៍ឡើងយ៉ាងខ្លាំង រ៉ឹងៗ ទីណូភ្ញាក់ពត់ខ្លួនប្រាណ ហើយនិយាយអរគុណនាឡិកាដែលបានដាស់។ ទីណូរត់ចេញទៅក្រៅ ឃើញព្រះអាទិត្យរះនិងឮសំឡេងសត្វយំអឺងកង។ ទីណូចូលបន្ទប់ទឹកលុបមុខ សិតសក់ ស្លៀកពាក់ស្អាតបាតស្រស់ស្រូបអាហារពេលព្រឹក រួចយកកាតាប សំពះលាប៉ាម៉ាក់ចេញទៅសាលារៀន។ គ្រាន់តែចូលបានផុតមាត់ទ្វាររបងសាលារៀន ជួងបន្លឺម៉ឺងៗ សិស្សទាំងអស់គោរពទង់ជាតិ រួចតម្រៀបជួរចូលថ្នាក់រៀន។ កូនស្វាមកដល់ចូលទៅអង្គុយជិតទីណូ។ គ្រូសួរសិស្ស **កូនស្វាតើឯងរវល់ធ្វើអ្វីបានជាទើបមកដល់? បាទខ្ញុំរវល់រកសៀវភៅ។ ថ្ងៃក្រោយ ឯងត្រូវរៀបចំទុកជាក់ប្រដាប់ប្រដារៀនសូត្រឱ្យមានរបៀបទើបងាយរក។**

(ដកស្រង់ពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

ជំពូកទី៣

រឿង ខ្លាឆ្លៀវតេពីរ

មានថ្ងៃមួយ តេពីរចាប់បានត្រីមួយនៅក្នុងបឹង។ តេទាំងពីរចែកត្រីគ្នាមិនដាច់ស្រេចសោះ ព្រោះវាចង់បានចំណែកខាងក្បាលដូចគ្នា។ ពេលនោះ មានខ្លាមួយដើរមកដល់។ ក្រោយពីរបានដឹងរឿង ខ្លាបានធានាខ្លួនធ្វើជាមេចំណែក។ ខ្លាកាត់ត្រីជាបីកង់គឺ ក្បាល ខ្លួន និងកន្ទុយ។ ឯកង់ខ្លួនត្រីមានសាច់ច្រើន។ ខ្លាហុចក្បាលទៅឱ្យតេទីមួយ ហើយកន្ទុយឱ្យទៅតេទីពីរ ដោយនិយាយថា **អ្នកខាងនេះបានក្បាល អ្នកខាងនោះបានកន្ទុយ។ ចំណែកខ្ញុំជាអ្នកចែក ខ្ញុំហត់ខ្លាំងណាស់ ខ្ញុំយកកង់ខាងខ្លួននេះហើយ។** និយាយចប់ ខ្លាក៏កាន់ចំណែករបស់ខ្លួនដើរចេញទៅ។ តេទាំងពីរនឹកស្តាយក្រោយយ៉ាងខ្លាំង។

(ដកស្រង់ពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

ជំពូកទី៤

រឿង ឧន្សាយចង់ស៊ីចេក

ទន្សាយឃើញយាយទូលចេកដើរមក ក៏ធ្វើពុតជាងាប់តាមផ្លូវ។ យាយឃើញទន្សាយងាប់ ត្រេកអរណាស់ក៏រើសទន្សាយដាក់ក្នុងល្អីចេក ហើយទូលដើរទៅ។ នៅតាមផ្លូវទន្សាយស៊ីចេកទាល់តែអស់ រួចលោតចូលព្រៃបាត់។ លុះមកដល់ផ្ទះ យាយដាក់ល្អីចុះ ស្រាប់តែឃើញនៅសល់តែសម្បកចេក។ យាយលាន់មាត់ **យីអើ! អញចាញ់បោកទន្សាយទេតើ!**

(ដកស្រង់ពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី១ បោះពុម្ពឆ្នាំ២០០៨)

រឿង ដឹងសងដឹង អំបែងសងអំបែង

មានបុរសពីរនាក់ប្តីប្រពន្ធមានកូនប្រុសម្នាក់។ ថ្ងៃមួយ បុរសបានខ្ចីដឹងរបស់សេដ្ឋីយកទៅកាប់អុស ចៃដន្យផ្លែដឹងរបូតទៅត្រូវប្រើសមួយកប់បាត់ក្នុងខ្លួនប្រើស វាក៏រត់បាត់ទៅ។ បុរសត្រឡប់មកផ្ទះវិញ ប្រាប់រឿងរ៉ាវឱ្យប្រពន្ធកូនដឹងទាំងចិត្តបារម្ភ ព្រោះមិនដឹងបានអ្វីយកទៅសងលោកសេដ្ឋី។ ប្រពន្ធក៏ពិបាកចិត្ត ព្រោះខ្លួនក្រីក្រមិនដឹងថា លោកសេដ្ឋីឱ្យសងប្រាក់ប៉ុន្មានទេ។

បុរសទៅសំពះសុំទិញដឹងថ្មីសងលោកសេដ្ឋី ប៉ុន្តែលោកសេដ្ឋីមិនព្រម ហើយប្រាប់ថា **ដឹងនោះជាដឹងកម្សត់កម្រពីដូនតា បើមិនបានដឹងចាស់របស់គាត់វិញទេ ទោះសងជាប្រាក់ប៉ុន្មានទ្វេដងក៏លោកសេដ្ឋីនៅតែមិនព្រម។** ទាល់តម្រិះបុរសមកពិគ្រោះជាមួយប្រពន្ធ យកកូនប្រុសទៅឱ្យនៅជាមួយលោកសេដ្ឋីជាសំណង។ កូនប្រុសអាណិតឪពុកខ្លាំងណាស់ យល់ព្រមចូលខ្លួនទៅបម្រើលោកសេដ្ឋី មិនថាការងារធ្ងន់ស្រាលបែបណាឡើយ។

ពេលបានកូនប្រុសរបស់បុរសមកនៅបម្រើ ទើបលោកសេដ្ឋីយល់ព្រមទទួល។ លោកសេដ្ឋីកំណត់ឱ្យកូនប្រុសបុរសនៅបម្រើមួយជីវិត ព្រោះតែផ្លែដឹងមួយប៉ុណ្ណោះ។ បុរសពីរនាក់ប្តីប្រពន្ធកើតទុក្ខខ្លាំងណាស់ មិនដឹងជួយកូនរបៀបណា។

ជាភ័ព្វសំណាងល្អ បុរសបានទៅកាប់អុសនៅម្តុំព្រៃថ្ងៃមុន ហើយបានជួបប្រើសដែលមុតផ្លែដឹងស្លាប់នៅទីនោះ បុរសក៏យកផ្លែដឹងកប់ក្នុងពោះប្រើសបានមកវិញ។ បុរសបានយកដឹងទៅសងលោកសេដ្ឋី ហើយសុំយកកូនប្រុសត្រឡប់មកផ្ទះវិញ។ លោកសេដ្ឋីគ្មានពាក្យអ្វីដោះសាទៀតទេ ហើយទើបយល់ព្រមប្រគល់កូនប្រុសឱ្យបុរសវិញ។

ដល់រដូវស្រូវទុំ ផ្ទះរបស់បុរសនាំគ្នាជាល់អំបុកហូប។ ក្លិនអំបុកឈ្ងុយឈ្ងប់ដល់ផ្ទះសេដ្ឋី ធ្វើឱ្យកូនក្រមុំលោកសេដ្ឋីនឹកឃ្លានចង់ហូបអំបុកស្រូវថ្មី ប៉ុន្តែនាងរកអំបែងមកជាល់អំបុកមិនបានសោះ។ នាងឱ្យឪពុកជួយរកអំបែងយកមកជាល់អំបុក លោកសេដ្ឋីរកមិនបាន ក៏ទៅខ្ចីអំបែងពីបុរសប្តីប្រពន្ធនោះឱ្យកូន។ បុរសនិងភរិយានៅចាំអំពើដែលសេដ្ឋីធ្វើមកលើគ្រួសារខ្លួនមិនភ្លេចទាល់តែសោះ ប៉ុន្តែគាត់មិនចង់តបពុតសេដ្ឋីវិញទេ ទោះបីសេដ្ឋីធ្លាប់ធ្វើបាបគ្រួសារគាត់ ព្រោះតែបាត់ផ្លែដឹងមួយឱ្យយកកូនទៅសងត្រូវបម្រើសេដ្ឋីមួយជីវិតក៏ដោយ។

បុរសព្រមប្រគល់អំបែងឱ្យលោកសេដ្ឋីខ្ចី លោកសេដ្ឋីបានអំបែងត្រែកអរណាស់ ក្នុងផ្ទះលោកមានរបស់មានតម្លៃរាប់មិនអស់ ប៉ុន្តែមកខ្វះអំបែងមួយទៅវិញ។ មនុស្សយើងជួនកាលមានទ្រព្យច្រើនពិតមែន តែត្រូវមានការពឹងពាក់គ្នាទៅវិញទៅមកជៀសមិនផុតឡើយ។ កូនស្រីសេដ្ឋីកំពុងលីងស្រូវដាល់អំបុក ស្រាប់តែមានឆ្កែខាំគ្នាមកជាន់អំបែងរបស់បុរសបែកអស់។ នាងនឹកហួសចិត្តនឹងឆ្កែខ្លាំងណាស់ មិនគួរមានរឿងចៃដន្យបែបនេះ។ ទីវាលមុខផ្ទះស្រឡះល្វឹងល្វើយមិនខាំគ្នា បែរជាមកខាំគ្នាជាន់ចំអំបែងបែកអស់ខានដាល់អំបុកទៅវិញ។

លោកសេដ្ឋីយកអំបែងបែកទៅបង្ហាញបុរស រួចសុំទិញអំបែងថ្មីសង។ ម្តងនេះបុរសមិនព្រមទទួលសំណងវិញម្តងគាត់ទាមទារយកតែអំបែងចាស់របស់គាត់វិញ។ បុរសប្រាប់លោកសេដ្ឋីថា **អំបែងនេះជារបស់ចាស់តាំងពីឪពុកម្តាយរបស់គាត់ទោះសងអំបែងថ្មីប៉ុន្មានក៏គាត់មិនត្រូវការដែរ។** បុរសនិងលោកសេដ្ឋីនាំគ្នាទៅប្តឹងចៅក្រមឱ្យជួយកាត់សេចក្តីឱ្យ។ ចៅក្រមបានកាត់ក្តីឱ្យលោកសេដ្ឋីទិញអំបែងថ្មីសងបុរសវិញ ព្រោះគ្មានអ្នកណាអាចរកអំបែងចាស់ ដែលបែកទៅហើយមកសងវិញបានឡើយ។ បុរសមិនសុខចិត្តចំពោះការកាត់ក្តីនេះទេ ព្រោះចៅក្រមលម្អៀងទៅខាងលោកសេដ្ឋី ដែលជាអ្នកមានទ្រព្យសម្បត្តិ។

បុរសនាំលោកសេដ្ឋីចូលគាល់ព្រះរាជា ទូលសុំឱ្យព្រះអង្គរកយុត្តិធម៌ឱ្យ។ ព្រះរាជាក៏គ្រាស់សួរដើងអស់ដំណើររឿងកន្លងមក។ ព្រះអង្គទ្រង់ឆ្វេងយល់ហើយកាត់ក្តីដោយព្រះបញ្ញាញាណ។ បុត្រីរបស់សេដ្ឋីត្រូវទៅនៅបម្រើគ្រួសារបុរសនោះវិញជំនួសអំបែងដែលបែក ដូចកាលលោកសេដ្ឋីឱ្យគេយកកូនប្រុសមកជំនួសដឹងបាត់ដូចគ្នា។ ទាំងនេះ ដូចពាក្យចាស់

ទូន្មានថា ចេះឯងឱ្យក្រែងចេះគេ។ លោកសេដ្ឋីទាល់គំនិត ត្រូវគោរពតាមការកាត់ក្តីរបស់ព្រះរាជា ប្រគល់កូនស្រីឱ្យទៅនៅជាមួយគ្រួសារបុរសវិញម្តង។

(ដកស្រង់ពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៣)

ជំពូកទី៥

រឿង ទន្សាយរត់ប្រណាំងជាមួយអណ្តើក

នៅក្នុងបឹងមួយមានអណ្តើកមួយគូជាប្តីប្រពន្ធនឹងគ្នា។ ថ្ងៃមួយ អណ្តើកប្តីបានជួបនឹងទន្សាយមួយក្នុងស្រែក្បែរមាត់បឹង។ ពេលនោះទន្សាយបានស្រែកសួរទៅអណ្តើក៖ **«សួស្តី! បងអណ្តើក! តើបងអញ្ជើញទៅណាមកណាហ្នឹង? យី! ដំណើរបងឯងគឹមៗល្អមើលណាស់! មើលចុះជើងបងខ្លីៗ។ ចំណែកខ្ញុំមានជើងវែងហើយរត់បានលឿនទៀតផង។ គ្មាននរណារត់ឈ្នះខ្ញុំឡើយ»**។ អណ្តើកខឹងនឹងទន្សាយខ្លាំងណាស់ ក៏និយាយទៅកាន់ទន្សាយ៖**«បើអ៊ីចឹងរត់ប្រណាំងគ្នាមើលទៅ។ តើបងទន្សាយហ៊ានរត់ប្រណាំងជាមួយខ្ញុំដែរឬទេ?**

ទន្សាយតប៖ **«ខ្ញុំហ៊ាន។ តើបងចាប់ផ្តើមរត់នៅពេលណា? ហើយនៅទីកន្លែងណា?»។** អណ្តើកឆ្លើយ៖ **«ថ្ងៃស្អែកនេះនៅចម្ការតោពៅ»។** ទន្សាយនិយាយ៖**«យល់ព្រម ខ្ញុំនឹងចាំបងនៅទីនោះ»។**

ក្រោយមក សត្វទាំងពីរក៏បែកផ្លូវគ្នាទៅកាន់កន្លែងរៀងៗខ្លួន។ ពេលធ្វើដំណើរតាមផ្លូវទៅកាន់ផ្ទះ អណ្តើកដើរបណ្តើរខំគិតរកមធ្យោបាយបណ្តើរ ដើម្បីរត់ឱ្យឈ្នះទន្សាយ។ លុះមកដល់ផ្ទះ អណ្តើកបានហៅប្រពន្ធខ្លួនមកហើយនិយាយ៖**«ស្អែកបងនឹងរត់ប្រណាំងជាមួយទន្សាយ បងចង់ឱ្យអូនជួយបង»។** ប្រពន្ធអណ្តើកសួរ៖**«តើបងចង់ឱ្យខ្ញុំជួយដូចម្តេច?»** អណ្តើកជាប្តីតប៖**«ងាយទេអូន! បងរត់ប្រណាំងជាមួយទន្សាយនៅឯចម្ការតោពៅ ដែលមានដីទើបតែភ្ជួររួចហើយ។ អូននិងបងដូចគ្នាណាស់ យើងនៅចុងចម្ការម្ខាងម្នាក់។ ពេលចាប់ផ្តើមរត់ជាមួយទន្សាយ បងរត់តែពីរ បីជំហាន រួចក្រាបចុះនៅនឹងគន្លងដី។ ចំណែកអូន នៅខាងចុងនោះរង់ចាំមើលទន្សាយ។ ពេលទន្សាយរត់ជិតដល់ អូនត្រូវងើបឡើងហើយនិយាយថា អញដល់ទីមុន»។**

បន្ទាប់ពីបានស្តាប់ការពន្យល់របស់អណ្តើកជាប្តីរួចមក អណ្តើកមេតបវិញថា៖**«ខ្ញុំយល់ថាព្រមជួយបងហើយ។ ចុះបើទន្សាយចង់រត់ប្រណាំងម្តងទៀត តើយើងត្រូវធ្វើដូចម្តេច?»** អណ្តើកជាប្តីឆ្លើយថា៖ **«ពេលនោះអូនយល់ព្រមរត់ជាមួយវា តែត្រូវធ្វើដូចបងប្រាប់គឺរត់តែពីរ បីជំហានរួចក្រាបចុះ។ ឯបងនៅចុងម្ខាងទៀតក្រោកឡើង រួចស្រែកថា អញដល់ទីមុន»។** ការពិភាក្សាប្តូរយោបល់រវាងអណ្តើកប្តីប្រពន្ធបានយល់ការកិច្ចរៀងៗខ្លួន។ ថ្ងៃរត់ប្រកួតរវាងអណ្តើកនិងទន្សាយបានចូលមកដល់។ ទន្សាយនិងអណ្តើកនៅឃ្លាតពីគ្នាប្រមាណជាបីម៉ែត។

ការប្រកួតចាប់ផ្តើម។ អណ្តើកជាប្តីរត់បានបន្តិចក៏ក្រាបចុះរត់តាមគន្លង។ ចំណែកទន្សាយខំរត់បោលទៅមុខ។ ពេលជិតទៅដល់ទី ទន្សាយងាកមើលអណ្តើកមិនឃើញក៏ស្រែកហៅ **«អឺបងអណ្តើក!»។** ពេលនោះប្រពន្ធអណ្តើកនៅពីមុខងើបឡើងរួចឆ្លើយថា **«គូកអញដល់ទីមុន!»។**

លើកនេះទន្សាយនឹកមិនអស់ចិត្តក៏បបួលអណ្តើករត់ឡើងវិញម្តងទៀត ទន្សាយចាញ់ដដែល។ ទន្សាយនៅតែបបួលអណ្តើករត់ទៀត។ សត្វទាំងពីររត់ប្រណាំងគ្នាបកទៅបកមក អស់មួយព្រឹកធំតែអណ្តើកនៅតែឈ្នះដដែល។ ទន្សាយអស់កម្លាំងខ្លាំងណាស់ តែដោយមានៈចង់ឈ្នះអណ្តើកពេក ទន្សាយនៅតែរត់ប្រណាំងជាមួយអណ្តើក រហូតដល់ដួលប្រកាច់លើដី ហើយក្សយជីវិតក្នុងការរត់ប្រណាំងនោះទៅ។

(ដកស្រង់ពីសៀវភៅភាសាសម្រាប់គ្រូថ្នាក់ទី៤ បោះពុម្ពឆ្នាំ ២០០១)

ជំពូកទី៧
រឿង អូនខ្លាឃ្មុំដ៏ឆ្លាហាន

ពូសុខនិងមីងនួនជាប្តីប្រពន្ធនឹងគ្នា គាត់មានមុខរបរជាអ្នកត្បាញហូលលក់។ ថ្ងៃមួយត្រល់របស់គាត់បានបាក់ ពូសុខក៏ចេញទៅរកឈើដើម្បីធ្វើត្រល់ថ្មី។ ពេលរៀបចេញដំណើរមកផ្ទះវិញគាត់ប្រទះនឹងកូនខ្លាឃ្មុំមួយមានរបួសជើង។ អាណិតកូនខ្លាឃ្មុំពេក គាត់ក៏សម្រេចចិត្តយកវាមកចិញ្ចឹម។ មកដល់ផ្ទះ ពូសុខបង្ហាញប្រពន្ធ **«អូនមើលនែ! តើបងយកអ្វីមក»?** មីងនួនតប **«អូ! កូនខ្លាឃ្មុំទេតើ! អីយ៉ា វាមានរបួសធ្ងន់ណាស់ ឱ្យមកអូនមកអូនយកវាទៅរុំរបួស»។**

ច្រើនថ្ងៃក្រោយមក កូនខ្លាឃ្មុំបានជាសះស្បើយ។ ពូសុខនិងមីងនួនសប្បាយចិត្តណាស់ គាត់ស្រឡាញ់កូនខ្លាឃ្មុំទុកដូចជាកូនរបស់គាត់។ ខ្លាឃ្មុំធំធាត់យ៉ាងឆាប់រហ័ស វាលែងជាកូនខ្លាឃ្មុំទៀតហើយ។ វាតែងជួយធ្វើការងារផ្ទះជានិច្ច។ វាជួយរវៃអំបោះ ជួយលើកសម្ភារៈដែលធ្ងន់ៗ និងធ្វើការផ្សេងទៀតតាមតែវាអាចធ្វើបាន។ ពូសុខនិងមីងនួន ហាក់មានជំនួយការដ៏ពិសេសមួយ គាត់សប្បាយចិត្តណាស់។ គាត់បានរៀបចំគ្រែដេកយ៉ាងល្អនៅក្បែរបង្អួចសម្រាប់ខ្លាឃ្មុំ។

ថ្ងៃមួយ មានចោរពីរនាក់ដឹងថាពូសុខ និងមីងនួនមិននៅផ្ទះពួកវាក៏មានគម្រោងនឹងលួចសម្ភារៈត្បាញរបស់គាត់។ ចោរនោះមិនចាប់អារម្មណ៍ពីខ្លាឃ្មុំនៅក្នុងផ្ទះនោះឡើយ។ យប់ស្ងាត់ ឃើញបង្អួចបើក ចោរទាំងពីរក៏ជាក់ជណ្តើរឡើងចូលតាមបង្អួច។ ខ្លាឃ្មុំដែលតែងតែដេកនៅក្បែរនោះ ឃើញសកម្មភាពចោរទាំងអស់ វានៅស្ងៀមដើម្បីឱ្យចោរចូលមកក្នុងផ្ទះឱ្យផុត។ ពេលចោរចូលហើយ វាលូកដៃច្រានជណ្តើរឱ្យរលំទៅក្រោម។ ខ្លាឃ្មុំ កាន់ដំបងដែលវាត្រៀមទុករហូតមក ហើយដើរលបៗទៅសំពងក្បាលចោរទី១ឮសូរ **«ភ្លស»។** ចោរនោះមើលមិនឃើញខ្លាឃ្មុំទេ វាគិតថាគ្នាវាជាអ្នកវាយ វាខឹងណាស់។ ខ្លាឃ្មុំលបៗទៅវាយចោរទី២ទៀត **«ភ្លស»។** ចោរទី២គិតថា ចោរទី១ជាអ្នកវាយ ចោរទាំងពីរគិតរៀងៗខ្លួនថាគ្នាវាក្បត់ រំពេចនោះឮសំឡេង **«ផ្ទួងផាំង»** បន្ទាប់មកចោរទាំងពីរដួលច្រងាប់ច្រងិលមានរបួសរៀងៗខ្លួន ក្រោកលែងរួច។

ព្រឹកឡើង ពូសុខនិងមីងនួនក៏ត្រឡប់មកវិញ ឃើញចោរដួលនិងអីវ៉ាន់រ៉ាប៉ាត់រ៉ាយ។ នៅក្នុងដៃខ្លាឃ្មុំមានកាន់ដំបងមួយឃាំងមិនឱ្យចោរចេញបាន។ វាញញឹមដាក់ម្ចាស់ទាំងពីរ ពួកគាត់សប្បាយចិត្តណាស់ ពេលនោះចោរទាំងពីរដែលតែងតែយាយីទ្រព្យសម្បត្តិអ្នកភូមិត្រូវបានដាក់ទោសតាមច្បាប់ហើយ។

(ដកស្រង់ពីសៀវភៅរឿងអប់រំសម្រាប់កុមារបោះពុម្ពដោយអង្គការមេត្តាករុណាកម្ពុជាឆ្នាំ២០១១)

ជំពូកទី៨
រឿង ទង្ហាប់ថ្មីរបស់ខ្ញុំ

វិចិត្រជាសិស្សថ្នាក់ទី៤។ ជារៀងរាល់ថ្ងៃ វាមានទម្លាប់មិនល្អសោះ។ ផ្ទះរបស់វិចិត្រនៅជិតសាលារៀនតែវាមិនដែលទៅរៀនទាន់ម៉ោង ហើយវាជាសិស្សខ្ជិលនិងរៀនខ្សោយជាងគេទៀត។ ថ្ងៃនេះ អ្នកគ្រូបានស្តីបន្ទោសវិចិត្រជាខ្លាំង។ មកដល់ផ្ទះវិញ វិចិត្របោះកាបូបព្រួសទៅលើគ្រែ។ មីងភីជាម្តាយឃើញក៏ឧទានឡើង **«ម៉េចហ្នឹងកូន ធ្វើមុខក្រញូវម្ល៉េះ? អ្នកគ្រូបន្ទោសទៀតហើយមែនទេ?»** វិចិត្រតបបណ្តើរដោះអាវគ្រវាត់បណ្តើរ **«មែនហើយម៉ែ នេះមកពីម៉ែមិនដាស់កូនហ្នឹងណា ធ្វើឱ្យកូនទៅសាលារៀនយឺត»។** មីងភីរអ៊ូតិចៗ **«យីកូននេះបន្ទោសឯងទៀត ចាំមើលព្រឹកស្អែកដាស់កូននេះពីព្រឹកបន្តិច»។**

ព្រឹកឡើង មីងភីដាស់វិចិត្រឱ្យក្រោករៀបចំខ្លួនទៅសាលារៀន**«វិចិត្រងើបឡើងកូន ជិតដល់ម៉ោងទៅសាលារៀនហើយ»។** វិចិត្រពត់ខ្លួន ហើយសំងំដេកបន្តិចទៀត។ មីងបន្ត **«ងើបឡើងៗ ជិតដល់ម៉ោងហើយ ទៅងូតទឹក រៀបចំខ្លួន** និង**ញ៉ាំអាហារពេលព្រឹកប្រយ័ត្នទៅរៀនយឺតទៀតណា»។** វិចិត្រពត់ខ្លួនម្តងទៀត រួចស្ទាប និងបើកភ្នែកម្ខាងមើលទៅនាឡិកា ហើយនិយាយ**«ឱ្យខ្ញុំដេកបន្តិចទៀតទៅម៉ែ»។** មីងឮដូចនេះ ស្ទុះទៅទាញភួយចេញពីវិចិត្រ រួចនិយាយ**«បើកូនមិនងើបទៅម៉ែនឹងទៅប្រាប់អ្នកគ្រូរបស់កូនហើយ»។** វិចិត្រឮដូចនេះក៏ងើបឡើង ព្រោះវានឹកឃើញពាក្យសន្យារបស់វាជាមួយអ្នកគ្រូកាលពីម្សិលមិញ។

មួយសន្ទុះវាស្រែកឡើង **«ម៉ែ! អាវកូននៅឯណា?»។** រកឃើញអាវ វារកស្រោមជើង រកឃើញស្រោមជើង វារកកាបូប ខ្មៅដៃ ប៊ិក សៀវភៅ ដំរលុប ... ក្រោយបង្អស់វាស្រែក **«ស្បែកជើងខ្ញុំម្ខាងទៀតនៅឯណា? ប្រហែលជាអាលុកពាំបាត់ហើយ»។** ទម្រាំរកអាវកាបូបស្បែកជើងម្ខាងឃើញ វាទៅរៀនយឺតដដែល។

អ្នកគ្រូស្តីបន្ទោសដល់វិចិត្រទៀត។ មិត្តរួមថ្នាក់របស់វិចិត្រក៏មិនចូលចិត្តវិចិត្រដែរព្រោះវាធ្វើឱ្យពួកគេខាតពេលឥតប្រយោជន៏។ វិចិត្រគិតតែម្នាក់ឯង **«តើខ្ញុំត្រូវធ្វើដូចម្តេចទើបមិត្តរួមថ្នាក់និងអ្នកគ្រូចូលចិត្តខ្ញុំទៅហ្ន៎?»។**

ថ្ងៃអាទិត្យមួយ វិចិត្របានមកលេងផ្ទះរបស់សីហា ដែលនៅឆ្ងាយពីសាលារៀន។ សីហារៀនថ្នាក់ទី៣ វាជាកុមារគំរូជាសិស្សពូកែហើយមិនដែលទៅសាលារៀនយឺតនោះទេ។ សីហាត្រូវជាប្អូនជីដូនមួយរបស់វិចិត្រ។ សីហាបាននាំ វិចិត្រចូលទៅបន្ទប់របស់ខ្លួនហើយបង្ហាញ **«នេះជាតុរៀនរបស់ខ្ញុំ នេះជាទូខោអាវ កន្លែងនេះខ្ញុំដាក់ទ្រនាប់ជើង នេះស្រោមជើង»។** វិចិត្រឃើញ ដូចនេះនឹកឃើញដល់របស់របរខ្លួនដែលនៅរាយប៉ាយមិនមានសណ្តាប់ធ្នាប់។ សីហានិយាយប្រាប់ដល់វិចិត្រ **«ពេលព្រឹក ខ្ញុំតែងក្រោកពីព្រលឹម រៀបចំខ្លួន និងញ៉ាំបបរ រួចទៅសាលារៀន ខ្ញុំមិនដែលទៅរៀនយឺតទេ ព្រោះខ្ញុំបានត្រៀមកាបូប និងសម្លៀកបំពាក់ ដែលត្រូវការរួចជាស្រេច»។** វិចិត្រមិនយល់នឹងសម្តីរបស់សីហានោះទេ វាគ្រាន់តែគិតថា **«សីហានៅតូចសោះ តែវាមានគំនិតនិងទម្លាប់ល្អណាស់ អញគួរតែកែទម្លាប់អាក្រក់ចេញហើយ»។**

មកដល់ផ្ទះ វិចិត្រខិតខំកែទម្លាប់របស់ខ្លួន ដោយខំរៀន និងរៀបចំប្រដាប់ប្រដារបស់ខ្លួនឱ្យ មានសណ្តាប់ធ្នាប់។ វាប្តេជ្ញាថា ថ្ងៃស្អែកនេះនឹងទៅរៀនឱ្យទាន់ម៉ោង និងឆ្លើយសំណួររបស់អ្នកគ្រូមិនឱ្យគាត់ស្តីបន្ទោសទៀតឡើយ។ មីងកីស្រែកឡើង **«ចិត្រកូនក្រោកឡើងជិតដល់ម៉ោងហើយ»។** វិចិត្រឮម្តាយហៅ វាធុញណាស់ ហើយកាន់តែឃ្លុំភួយបន្ថែមទៀត។ មីងហួសចិត្តនឹងកូនជាខ្លាំងហើយនិយាយអ៊ូថា **«កូនធំហើយ គួរចេះទទួលខុសត្រូវដោយខ្លួនឯង។ បើកូនខ្ជិលរៀនយ៉ាងនេះ តើកូននឹងធ្វើអ្វីទៅ?»។**

វិចិត្រឮដូចនេះ វានឹកឃើញដល់ការប្តេជ្ញារបស់វា។ វិចិត្រស្ទុះក្រោកឡើង ហើយម្តីម្នាងូតទឹក ស្លៀកពាក់ រៀបចំទៅសាលារៀន។ ថ្ងៃនេះវិចិត្រទៅទាន់ម៉ោង វាសប្បាយចិត្តណាស់។ មកដល់ផ្ទះ វាធ្វើមុខរីករាយជាក់ម្តាយ។ វាប្រាប់ម្តាយថា **«ម៉ែមិនបាច់ជាស់ខ្ញុំទៀតទេ ចាប់ពីពេលនេះទៅ ខ្ញុំនឹងកែទម្លាប់អាក្រក់របស់ខ្ញុំចោល»។**

ចាប់តាំងពីពេលនោះមកវិចិត្របានកែទម្លាប់អាក្រក់របស់វាបន្តិចម្តងៗ រហូតវាមានទម្លាប់ល្អ។ អ្នកគ្រូនិងមិត្តរួមថ្នាក់ជាពិសេសមីងកីសប្បាយចិត្តណាស់ហើយម្នាក់ៗចូលចិត្តវិចិត្រគ្រប់ៗគ្នា។

(ដកស្រង់ពីសៀវភៅរឿងអប់រំសម្រាប់កុមារបោះពុម្ពដោយអង្គការមេត្តាករុណាកម្ពុជាឆ្នាំ២០១១)

ជំពូកទី១០
រឿង ក្មេងគង្វាលចៀម

គីយោជាក្មេងគង្វាលចៀមម្នាក់នៅក្នុងភូមិមួយ។ រាល់ថ្ងៃ គីយោតែងតែទៅឃ្វាលចៀមនៅឆ្ងាយពីភូមិ។ អ្នកភូមិបានផ្តាំវាថា៖ **«បើមានសត្វសាហាវមករកស៊ីចៀមឯងត្រូវស្រែកហៅពួកយើងឱ្យខ្លាំងៗ។ ពេលពួកយើងឮ ពួកយើងនឹងទៅជួយ»។** គីយោយល់ព្រមរួចទៅឃ្វាលរាល់ថ្ងៃ។ យូរថ្ងៃក្រោយមកគីយោ កាន់តែអផ្សុកខ្លាំងឡើងៗ។ វាក៏នឹកឃើញពាក្យសម្តី ដែលអ្នកភូមិផ្តាំ។ គីយោក៏ឡើងលើដើមឈើ រួចស្រែកខ្លាំងៗថា៖ **«ជួយផង! ជួយផង! ឆ្កែចចកខាំចៀមស៊ីអស់ហើយ!»**ឮហើយ អ្នកស្រុករត់សំដៅទៅរកហ្វូងចៀម។ អ្នកខ្លះកាន់ ដំបង ខ្លះកាន់កាំបិត អ្នកខ្លះកាន់ពូថៅ។ ពេលពួកគេទៅដល់ គីយោអស់សំណើចហើយសើចលេងជាល្បែង។

ដោយឥតមានឃើញឆ្កែចចក អ្នកភូមិក៏ដឹងថា៖ **«គីយោភូតលេង»។** ទាំងអស់គ្នាអ៊ូខឹងនឹងក្មេងកុហកនេះ ហើយនាំគ្នាត្រឡប់ទៅភូមិវិញ។

ថ្ងៃក្រោយមក មានឆ្កែចចកធំមួយចេញមកស៊ីចៀម។ គីយោភ័យខ្លាំងណាស់។ វាស្រែកយ៉ាងពេញទំហឹងឱ្យអ្នកភូមិជួយ។ សម្រែកគីយោលាន់ឮយ៉ាងច្បាស់ តែអ្នកភូមិមិនអើពើនឹងសម្រែកនោះទេ។ ពួកគេគិតថា គីយោកំប្លែងលេងទៀតហើយ។

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី២បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី១៣
សម្រស់ភូមិខ្ញុំ

ព្រឹកព្រាងថ្ងៃរះភ្លឺច្បាស់ភូមិខ្ញុំ វាលស្រែស្រូវទុំភោគផលច្រើនណាស់ (ដង២)
ភូមិខ្ញុំល្អស្អាតប្រជាក្មេងចាស់ ឧស្សាហ៍រួតរះប្រកបការងារ អឺអើយៗ។

(ដកស្រង់ពីសៀវភៅភាសាខ្មែរថ្នាក់ទី២ បោះពុម្ពឆ្នាំ២០១០)

ជំពូកទី១៥
រឿង ខ្លែងមួយ

ពេលណាជីដូនមកលេងម្តងៗ បូផាសប្បាយណាស់។ ជារឿយៗមុនពេលចូលដំណេកយាយនិទានរឿងអោយចៅស្តាប់។ យប់មួយនោះ យាយនិយាយរឿង**ខ្លែងមួយ**។

កាលពីព្រេងនាយ មានខ្លែងមួយហើរក្រឡឹងរកអាហារ។ ថ្ងៃមួយនោះ វាបានឃើញមេមាន់មួយក្បាលកំពុងបណ្តើរកូនមួយរ៉ូង ចូលទៅរកចំណីស៊ីក្នុងវត្ត។ ខ្លែងឃើញហើយគិតក្នុងចិត្តថា**«ពិតជាមានលាភធំមែន»។** ខ្លែងសំយុងក្បាល បោះពួយយ៉ាងលឿនសំដៅរ៉ូងកូនមាន់។ ឯមេមាន់ឃើញភាពអាសន្នមកដល់ហើយ ក៏ប្រញាប់ស្រែកប្រាប់កូនវាអោយរត់ពួននៅតាមគុម្ពផ្កា។ ភ្លាមនោះ ខ្លែងបានបន្ទាបខ្លួនមកដល់ដី។ វាយកក្រញាំជើងចាប់ខាំកូនមាន់ ហើយហើរឡើងទៅលើអាកាសវិញយ៉ាងរហ័ស។

ពេលហើរទៅដល់លើអាកាស ទើបខ្លែងដឹងថាវាឆាបកូនមាន់មិនបានទេ ប៉ុន្តែបានសំរាមស្លឹកឈើមួយសន្លឹក។ ខ្លែងហើរយកស្លឹកឈើនោះ ទៅទម្លាក់ចោលនៅខាងក្រៅវត្ត។ រួចខ្លែងក៏ទៅរកចំណីនៅកន្លែងផ្សេងទៀត។

នៅពេលវាចាស់ស្លាប់ទៅវាបានទៅកើតនៅស្ថានសួគ៌ចំនួនមួយថ្ងៃ។ នេះដោយសារវាយកសំរាមបន្តិចចេញអំពីវត្ត

បូផាស្តាប់យាយនិទានរឿងចប់វាសួរថា **«លោកយាយ! ហេតុអ្វីបានជាខ្លែងបានឡើងស្ថានសួគ៌តិចថ្ងៃម្ល៉េះ?»**

យាយតប **«ព្រោះវាបានធ្វើអំពើល្អបានតែបន្តិច ឯការដែលវាសម្លាប់ជីវិតគេជាអំពើបាបណាចៅ។ ចៅត្រូវធ្វើអំពើល្អទើបបានបុណ្យ»។**

បូផាសួរយាយទៀតថា **«អូ! បើយើងធ្វើអំពើបាប យើងចុះនរកមែនឬទេ? លោកយាយឆ្លើយ មែនហើយចៅ»។**

(ដកស្រង់ពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី២ បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី១៦
រឿង សត្វត្មាត

កាលពីព្រេងនាយ នៅលើកំពូលភ្នំមួយ មានត្មាតបីគឺ ត្មាតម្តាយ ត្មាតឪពុកនិងត្មាតកូន។ ត្មាតម្តាយនិងត្មាតឪពុកចាស់ជរាជ្រុះស្លាបអស់ ពុំអាចហើរទៅណាបានទេ។ ត្មាតកូនតែងតែហើរទៅរកស៊ីតាមជើងភ្នំ ដើម្បីរកចំណីអាហារយកទៅចិញ្ចឹមម្តាយឪពុក។ ថ្ងៃមួយ កូនត្មាតហើរចុះពីកំពូលភ្នំ ទៅរកចំណីដូចធម្មតា។ ពេលនោះ វាប្រទះឃើញសាច់នៅក្នុង

អន្ធាក់។ វាប្រថុយហើរឆាបយកដុំសាច់នោះ។ ប៉ុន្តែសំណាងមិនល្អ វាក៏ជាប់អន្ធាក់។ ព្រានព្រៃចាប់ត្មាតបម្រុងនឹងសម្លាប់តែត្មាតនិយាយអង្វរព្រានព្រៃថា **«ឱ! បងព្រានព្រៃសូមបងកុំសម្លាប់ខ្ញុំ។ បើបងសម្លាប់ខ្ញុំម្នាក់ ដូចសម្លាប់បីនាក់ដែរ ព្រោះម្តាយឪពុកខ្ញុំសព្វថ្ងៃរស់នៅដោយសារខ្ញុំជាអ្នករកស៊ីចិញ្ចឹម»។** សម្តីនេះ ធ្វើឱ្យព្រានព្រៃភ្ញាក់គំនិត ពិចារណាថា**៖ «ឱ! ខ្ញុំអើយ ខំរកស៊ីសព្វថ្ងៃពុំបានជួយចិញ្ចឹមម្តាយឪពុកចាស់ជារាខ្ញុំសោះ។ ខ្ញុំគិតតែខ្លួនឯងប៉ុណ្ណោះ។** គិតដូចនេះហើយ ព្រានព្រៃលែងត្មាតទៅវិញ ហើយតាំងចិត្តចិញ្ចឹមម្តាយ ឪពុក ដូចសត្វត្មាតនេះដែរ»។

(ដកស្រង់ពីសៀវភៅភាសាខ្មែរគ្រូថ្នាក់ទី២ បោះពុម្ពឆ្នាំ១៩៩៧)

ផ្នែកទី៣

លំនាំនៃការបង្រៀន

សេចក្តីណែនាំ

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថាសិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាននិងសរសេរនៅមានកម្រិតទាបគួរឱ្យបារម្ភ។ ដើម្បីពង្រឹងគុណភាពនៃការអាន និងសរសេរឱ្យកាន់តែប្រសើរគណៈកម្មការបានធ្វើការសម្របសម្រួលវិធីសាស្ត្រនិងកែលម្អឯកសារបង្រៀនភាសាខ្មែរថ្នាក់ទី១ និងថ្នាក់ទី២របស់ក្រសួងអប់រំ យុវជន និងកីឡាមកជាសៀវភៅពន្លឿនការសិក្សាថ្នាក់ឆ្នាំទី១ ដើម្បីឱ្យសិស្សក្នុងកម្រិតនេះអាចអានភាសាខ្មែរ ឆាប់ចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សា។ សម្រាប់កម្រិតសិក្សាថ្នាក់ឆ្នាំទី១នេះត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែក ភាសាខ្មែរ ពោលគឺ៖ ចេះអាន សរសេរបានច្បាស់លាស់។

សៀវភៅសម្រាប់បង្រៀនភាសាខ្មែរកម្រិតសិក្សាថ្នាក់ឆ្នាំទី១នេះ រៀបរៀងឡើងដើម្បីសម្រួលដល់ការរៀននិងការបង្រៀនភាសាខ្មែរដោយដកស្រង់ខ្លឹមសារមួយចំនួននិងយកលំនាំសៀវភៅថ្នាក់ទី១និងថ្នាក់ទី២របស់ក្រសួងអប់រំ យុវជន និងកីឡា មកធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មីៗ។ សៀវភៅនេះចាប់ផ្តើមពីការរៀន **ស្រៈនិស្ស័យ ព្យញ្ជនៈផ្សំនឹងស្រៈ ព្យញ្ជនៈមានសញ្ញា(អ) (ំ) ព្យញ្ជនៈមានសញ្ញា(អ៊) (ិ) ប្រកប ព្យញ្ជនៈផ្ញើជើង ស្រៈពេញតួ ព្យាងតម្រួត អំណានមេសូត្រ និយាយ ស្តាប់ សំណេរ វេយ្យាករណ៍** ដើម្បីឱ្យសិស្សមានបំណិនរឹងមាំក្នុងការអាន ផ្សំព្យញ្ជនៈជាមួយស្រៈនិងឈានឆ្ពោះទៅប្រកប អានពាក្យ អានឃ្លានិងអានអត្ថបទ។

ដើម្បីជាជំនួយដល់ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សានេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតលើ៖

១. បង្រៀនអាននិងសរសេរស្រៈនិស្ស័យ (៤ម៉ោង)

- ឧទាហរណ៍ ៖ បង្រៀនស្រៈ "ា"

សកម្មភាពទី១៖ បង្ហាញស្រៈ "ា"

- បង្ហាញវត្ថុជាក់ស្តែង ឬរូបភាពដែលមានសូរស្រៈដែលត្រូវរៀននៅក្នុងនោះ ឬគ្រូអាចហៅឈ្មោះសិស្សដែលមានសូរស្រៈនោះក៏បាន ។ គ្រូលើកកាទឹកបង្ហាញសិស្ស ឱ្យសិស្សប្រាប់ឈ្មោះវត្ថុនោះ
- អានពាក្យ " កា " ដោយសង្កត់សូរសំឡេងស្រៈ "ា" ។ គ្រូអានស្រៈ [អា] ឱ្យសិស្សថាតាម
- លើកស្រៈចល័ត "ា" បង្ហាញសិស្សនិងឱ្យសិស្សអានស្រៈ [អា] ជាបុគ្គលរួចជាក្រុមក្រុម
- ប្រាប់ពាក្យដែលមានសូរ "ា" ដូចជាតាខាហើយឱ្យសិស្សរកពាក្យផ្សេងទៀតដែលមានសូរ "ា"
- ឱ្យសិស្សរកពាក្យដែលមានសូរ «ា» ។

សកម្មភាពទី២៖ សរសេរស្រៈ "ា"

- សរសេរស្រៈ "ា" នៅលើក្តារខៀនដោយមានសញ្ញាព្រួញអម
- ចង្អុលស្រៈ "ា" ឱ្យសិស្សអានម្នាក់ម្តងៗ រួចអានក្រុមតូច
- សរសេរស្រៈ "ា" ឱ្យសិស្សមើលព្រមទាំងនិយាយ ខ្ញុំគូសពីឆ្វេងទៅស្តាំ ពីលើចុះក្រោម។
- នាំសិស្សសរសេរស្រៈលើខ្យល់និងឱ្យសិស្សនិយាយបណ្តើរ។ គ្រូពិនិត្យផងក្រែងមានសិស្សធ្វើចលនាបញ្ច្រាសទិស
- ហៅសិស្ស ៣ - ៤នាក់ ឡើងសរសេរស្រៈ "ា" នៅក្តារខៀនរួចអាន។
- ឱ្យសិស្សសរសេរស្រៈ "ា" លើក្តារឆ្នូន។ គ្រូដើរពិនិត្យនិងកែលម្អសិស្សដែលសរសេរខុស។

ចំណាំ : សូមបង្រៀនសរសេរស្រៈផ្សេងទៀត ដោយធ្វើតាមលំនាំបង្រៀនស្រៈ ា ។
គ្រូមិនត្រូវបង្រៀនអានមួយថ្ងៃ ហើយសរសេរ មួយថ្ងៃដាច់ពីគ្នាទេ។

២. ល៎ំនាំបង្រៀនអានព្យញ្ជនៈ (២ម៉ោង)

សកម្មភាពទី១៖ ទំនាក់ទំនង

- បិទផ្ទាំងចម្រៀងអក្ខរក្រម នៅលើក្តារខៀន។ សួរសិស្សថា កូនឃើញអ្វីខ្លះ?
  តើកូនអាចអានអក្សរណាមួយបានឬទេ?

សកម្មភាពទី២៖ បង្ហាញព្យញ្ជនៈ

- ច្រៀងចម្រៀងមួយវគ្គឱ្យសិស្សស្តាប់ព្រមទាំងចង្អុលចំៗតួអក្សរ ក ខ គ ឃ ង។
- សួរអំពីអ្វីដែលគេស្តាប់ឮក្នុងវគ្គចម្រៀងនេះ។ ប្រាប់សិស្សថា សូរសំឡេងដែលឮនេះជាឈ្មោះតួអក្សរ។

វគ្គទី១ ឈ្មោះថាវគ្គ «ក ខ គ ឃ ង» ។

- ច្រៀងចម្រៀងមួយឃ្លាម្តងនិងឱ្យសិស្សច្រៀងតាម ដោយចង្អុលចំៗតួអក្សរ។
- ច្រៀងឡើងវិញ និងជំរុញសិស្សឱ្យច្រៀងតាមរហូតសិស្សអាចច្រៀងវគ្គនេះបាន។

ចំណាំ : ចំពោះវគ្គដទៃទៀត គប្បីបង្រៀនតាមលំនាំវគ្គទី១។ ក្នុងពេលនេះមិនទាន់តម្រូវឱ្យសិស្ស សរសេរ ក ខ ទេគឺគ្រាន់តែអានប៉ុណ្ណោះ។

សកម្មភាពទី៣៖ ហ្វឹកហាត់អាន

- អានសូរ [ក] រួចឱ្យសិស្សចង្អុលអក្សរ ក នៅលើផ្ទាំងចម្រៀង។ បន្ទាប់មកឱ្យសិស្សចង្អុលអក្សរ ក នៅលើតារាងព្យញ្ជនៈ ៣៣ តួ។
- ឱ្យសិស្សឡើងអានម្តងម្នាក់ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ។
- ចង្អុលព្យញ្ជនៈឆ្លាស់គ្នាឱ្យសិស្សអាន រួចឱ្យអានបញ្ច្រាស ឬប្រើវិធីសាស្ត្រផ្សេងទៀតក៏បាន ដើម្បីឱ្យ សិស្សចំណាំតួអក្សរបានច្បាស់។

៣. បង្រៀនអានឯកសរសេរព្យញ្ជនៈពួក "អ" ផ្សំនឹងស្រៈ

☆ ឧទាហរណ៍ ៖ ព្យញ្ជនៈ " ច ឆ" (២ម៉ោង)

សកម្មភាពទី១៖ បង្ហាញព្យញ្ជនៈ " ច ឆ"

- បង្ហាញសម្ភារៈជាក់ស្តែង រូបភាព ធ្វើកាយវិការ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬសួរសំណួរតម្រូវទៅតាមព្យញ្ជនៈដែលត្រូវរៀន។ ឱ្យសិស្សថាតាមព្យញ្ជនៈនោះ ៣-៤នាក់
- បង្ហាញអក្សរចល័ត ច រួចឱ្យសិស្សអានជាបុគ្គល
- សរសេរបណ្តើរនិយាយបណ្តើរពីអក្សរ ច នៅលើក្តារខៀនដោយប្រើគំនូសអក្សរធំៗ មួយគំនូសម្តងៗឱ្យបានច្បាស់ និងយឺតល្មម ដើម្បីឱ្យសិស្សអាចតាមដាន និងចំណាំទិសឡើងចុះបាន
- ដឹកនាំសិស្សសរសេរក្នុងខ្យល់
- ឱ្យសិស្ស ២ ឬ៣នាក់ឡើងសរសេរនៅក្តារខៀន
- ឱ្យសិស្សសរសេរព្យញ្ជនៈ ច លើក្តារឆ្នួន។ គ្រូត្រួតពិនិត្យនិងកែលម្អការសរសេររបស់សិស្ស

ចំណាំ : ចំពោះព្យញ្ជនៈ **ឆ** ឬផ្សេងទៀត គ្រូគប្បីបង្រៀនដូចព្យញ្ជនៈ **ច** ដែរ។

សកម្មភាពទី២៖ បង្ហាញព្យាង្គ

- លើកអក្សរចល័ត **ច** រួចសួរសិស្ស តើនេះជាអក្សរអ្វី? បង្ហាញស្រៈ ◌ា រួចសួរ នេះជាស្រៈអ្វី? គ្រូយក **ច** ផ្សំនឹងស្រៈ ◌ារួចអានជាគំរូ **ច** ◌ា **ចា** រួចឱ្យសិស្សថាតាម។ គ្រូសរសេរ **ចា** នៅក្តារខៀន
- បង្រៀនព្យញ្ជនៈ **ច** ផ្សំនឹងស្រៈ ◌ិ ដល់ស្រៈ **ោ**ះដោយធ្វើតាមលំនាំបង្រៀន **ច**និងស្រៈ ◌ា ដែរ។
- ចង្អុលនិងអានព្យាង្គម្តងមួយៗឱ្យសិស្សស្តាប់ដូចខាងក្រោមៈ
- **ច ◌ា ចា, ច ◌ិ ចិ, ច ◌ី ចី , ចឹ ចឹ , ចឹ ចឹ**.....**ច ោ**ះ **ចោៈ**។
- ដឹកនាំសិស្សអានពីដើមដល់ចប់ ដោយចង្អុលតាមលំដាប់ រួចបញ្ច្រាសមកវិញ រួចធ្លាស់ចុះឡើង។
- ចង្អុលនិងអានមិនបាច់ប្រកប ឱ្យសិស្សថាតាមដូចខាងក្រោមៈ **ច ចា ចិ ចី ចឹ ចឹ ចុ ចូ**.....**...ចោៈ**។
- ឱ្យសិស្សអានជាបុគ្គលនិងជាក្រុម(១ក្រុមមិនលើសពី ៥នាក់)។

ចំណាំ : ចំពោះព្យញ្ជនៈ **ឆ** ឬផ្សេងទៀត គ្រូគប្បីបង្រៀនដូចព្យញ្ជនៈ **ច** ដែរ។

សកម្មភាពទី៣ៈ បង្ហាញពាក្យនិងកន្សោមពាក្យ

- បង្ហាញសម្ភារៈជាក់ស្តែង រូបភាព ធ្វើកាយវិការ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬសួរសំណួរតម្រូវទៅតាមពាក្យដែលត្រូវរៀន។ ឱ្យសិស្សថាតាមពាក្យនោះ៣-៤នាក់។
- បង្ហាញប័ណ្ណពាក្យ រួចឱ្យសិស្សអានជាបុគ្គល។
- នាំសិស្សបំបែកពាក្យដោយសួរសិស្សថា តើពាក្យ ឆា មានព្យញ្ជនៈនិងស្រៈអ្វីខ្លះ?
- ប្រើអក្សរចល័តបំបែកពាក្យឱ្យសិស្សមើល។ ឧទាហរណ៍ៈ ឆា
- នាំសិស្សផ្សំព្យញ្ជនៈនឹងស្រៈឱ្យសិស្សថាតាម ។ ឧទាហរណ៍ៈឆ ◌ា→ឆា

ចំណាំ : ឯការបង្រៀនពាក្យដទៃធ្វើដូចបង្រៀនពាក្យ "ឆា" ដែរ។

- **ការបង្រៀនពាក្យពីរព្យាង្គ**"ចរចា" ដោយបង្ហាញសម្ភារៈ រួចបង្ហាញពាក្យ។
- ការបំបែកពាក្យជាព្យាង្គ ឧទាហរណ៍ **ចរចា**
- ការផ្សំព្យាង្គ។ ឧទាហរណ៍ **ច រ ច ◌ា →ចរចា**
- អានពាក្យខាងលើឱ្យសិស្សអានតាមម្តងមួយជួរ។

ចំណាំ : ឯការបង្រៀនពាក្យដទៃធ្វើដូចបង្រៀនពាក្យ **"ចរចា"**ដែរ។

ចំពោះពាក្យ **ចាប ឆក ចក ចចក ចឹក ចេក**ឱ្យសិស្សអានមិនបាច់ប្រកប។

សកម្មភាពទី៤ៈ បង្ហាញល្បែៈ

- បង្ហាញផ្ទាំងរូបភាព បំផុសសំណួរ កាយវិការ ដើម្បីឱ្យសិស្សបង្កើតល្បែៈ។
- បង្ហាញល្បែៈដាក់លើក្តារខៀន។ ដោយបំបែកល្បែៈជាផ្នែកតូចៗ (ពាក្យ) ដើម្បីឱ្យសិស្សងាយអាន។ ឧទាហរណ៍ៈ ចែ ឆាំ ចេៈ ឆា។ តើល្បែៈនេះមានប៉ុន្មានពាក្យ? (៤ពាក្យ) តើពាក្យ "ចែ" មានអក្សរអ្វីខ្លះ?...
- ឱ្យសិស្សអានពាក្យនីមួយៗដោយប្រកបដូចខាងក្រោមៈ ចអែចែ, ឆ អាំ ឆាំ,ច អេៈ ចេៈ, ឆ អា ឆា ចែ ឆាំ ចេៈ ឆា។

ចំណាំ : ឯការបង្រៀនល្បែៈដទៃធ្វើដូចបង្រៀនល្បែៈ**"ចែឆាំចេៈឆា។ "**ដែរ។

សកម្មភាពទី៥ៈ ហ្វឹកហាត់អាន

- ចង្អុលពាក្យធ្លាស់ចុះ ធ្លាស់ឡើងនៅលើក្តារខៀនឱ្យសិស្សអានជាបុគ្គល និងក្រុមតូចៗ។

៤. បង្រៀនអាននិងសរសេរព្យញ្ជនៈពួក "អ" ផ្សំនឹងស្រៈ

លំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈ គប្បីធ្វើតាមលំនាំបង្រៀនដូចព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈដែរ គ្រាន់តែការអានមានសូរសំឡេងខុសគ្នាដូចខាងក្រោមៈ ដំបូងគ្រូប្រាប់សិស្សថា ◌ា ◌ិ ◌ី... ◌ោៈ ។ កាលណាប្រើជាមួយព្យញ្ជនៈពួក [អ] ដូចជា គ ឃ ង ... ត្រូវដូរសំឡេងជា អា អុិ អុី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ អោ អៅ អុំ អំ អាំ អ៊ៈ អ៊ុៈ អេ៊ៈ អោ៊ៈ។ គ្រូគប្បីនាំសិស្សអាន អ អា...អោៈ សិន។

គ អា គា	គ អុិ គិ	គ អុី គី	គ អឹ គឹ	គ អឺ គឺ	គ អុ គុ
គ អូ គូ	គ អួ គួ	គ អើ គើ	គ អឿ គឿ	គ អៀ គៀ	គ អេ គេ
គ អែ គែ	គ អៃ គៃ	គ អោ គោ	គ អៅ គៅ	គ អុំ គុំ	គ អំ គំ
គ អាំ គាំ	គ អ៊ៈ គ៊ៈ	គ អ៊ុៈ គ៊ុៈ	គ អេ៊ៈ គេ៊ៈ	គ អោ៊ៈ គោ៊ៈ។	

គា គិ គី គុ គូ គួ គើ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គ៊ៈ គ៊ុៈ គេ៊ៈ គោ៊ៈ។

៥. បង្រៀនព្យញ្ជនៈមានសញ្ញា (អ)

☆ ឧទាហរណ៍ ៖ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉(៤ម៉ោង)

សកម្មភាពទី១៖ បង្ហាញព្យញ្ជនៈ

- បង្ហាញផ្ទាំងព្យញ្ជនៈដូចខាងក្រោមនេះ។

ង	ង៉
ញ	ញ៉
ប	ប៉
ម	ម៉
យ	យ៉
រ	រ៉
វ	វ៉

- ចង្អុលអក្សរ ង ញ ប ម យ រ វ ម្តងមួយតួ រួចសួរសិស្សថា នេះជាអក្សរអ្វី?
- ចង្អុលអក្សរម្តងមួយគូៗនិងបញ្ចេញសំឡេងឱ្យសិស្សស្តាប់និងថាតាម។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ។ ឧទាហរណ៍ ង ង៉។
- សួរសិស្សថា: គូទី១ ក្នុងតារាងខាងលើមានសំឡេងខុសគ្នាដូចម្តេច? តើវាខុសគ្នាដោយសារអ្វី? ដោយសារមានសញ្ញា (◌៉) គ្រូប្រាប់សិស្សថា (◌៉) គេហៅថាសញ្ញា (អ) ឬធ្មេញកណ្តុរ ឬម៉ូសិកទន្ត។ កាលណាវាជាក់លើ **ង**ទៅជា **ង៉** , **ញ** ទៅជា **ញ៉** (មានសំឡេងអ)កាលណាវានៅជាមួយស្រៈ «◌ិ ◌ី ◌ឹ ◌ឺ ◌ើ◌ាំ» វាដូរទៅជា «◌ុ» វិញ។ ឧទាហរណ៍ : **ញ៉** អាំ **ញ៉ាំ** , ចា ប៉ ◌ី **ប៉ី ចាប៉ី**។
- ដឹកនាំសិស្សអាន **ង** សម្លាប់ពីរ **ង៉**, **ញ** សម្លាប់ពីរ **ញ៉** ... ឱ្យសិស្សថាតាមម្នាក់ម្តង រួចជា ក្រុមទូទាំងថ្នាក់។

សកម្មភាពទី២ ៣ ៤និង៥ សូមធ្វើតាមលំនាំបង្រៀនដូចព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈដែរ។

៦. បង្រៀនព្យញ្ជនៈអានសញ្ញាត្រីស័ព្ទ

ចំណាំ : សូមលោកគ្រូអ្នកគ្រូបង្រៀនតាមលំនាំបង្រៀនមូសិកទន្ត ឬធ្មេញកណ្តុរ

៧. បង្រៀនស្រៈពេញតួ (៤ម៉ោង)

↳ ឧទាហរណ៍ ៖ អ អា ឥ ឱ ...

សកម្មភាពទី១៖ បង្ហាញស្រៈពេញតួ

- បិទ ឬសរសេរស្រៈពេញតួលើក្តារខៀន។
- អានជាគំរូ ឱ្យសិស្សថាតាម។
- ឱ្យសិស្សអានជាបុគ្គល ៤-៥នាក់រួចឱ្យសិស្សអានជាក្រុមតូចៗ។
- ចង្អុលព្យញ្ជនៈឆ្លាស់គ្នាឱ្យសិស្សអាន រួចឱ្យអានបញ្រ្ចាស ឬប្រើវិធីសាស្ត្រផ្សេងទៀតក៏បាន ដើម្បីឱ្យសិស្សចំណាំតួអក្សរបានច្បាស់។

សកម្មភាពទី២ ៣ ៤និង៥ សូមធ្វើតាមលំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈ។

៨. បង្រៀនអាននិងសរសេរព្យញ្ជនៈផ្ញើជើង

ឧទាហរណ៍ ៖ ព្យញ្ជនៈផ្ញើជើង "ក្ប" (២ម៉ោង)

សកម្មភាពទី១៖ បង្ហាញរបៀបផ្សំ

- បង្ហាញព្យញ្ជនៈ ក ចល័ត រួចសួរ តើនេះជាព្យញ្ជនៈអ្វី? គ្រូបង្ហាញជើង ◌្ប ចល័ត រួចសួរ នេះជាអ្វី? គ្រូយក ក ដាក់លើជើង ◌្ប រួចឱ្យសិស្សអានឱ្យស្តាប់ ឬគ្រូអាន ។ ឱ្យសិស្សថាតាមទាំងអស់គ្នា ។ សិស្សថាជាក្រុមតូចៗ ។

សកម្មភាពទី២៖ បង្ហាញព្យញ្ជនៈនិងព្យាង្គ

- លើកព្យញ្ជនៈចល័ត **ក្ប** រួចសួរសិស្ស តើនេះជាព្យញ្ជនៈអ្វី? គ្រូអានជាគំរូ **ក្ប** រួចឱ្យសិស្សថាតាម ជាបុគ្គល ជាក្រុមតូចៗ។
- យកស្រៈ ◌ា ◌ិ ◌ី ◌ឹ ◌ឺ មកផ្សំជាមួយ ក្ប : ក្បា ក្ប្ិ ក្ប្ី ក្ប្ឹ ... ម្តងមួយៗ ហើយអានឱ្យសិស្សស្តាប់ ឱ្យសិស្សជាក្រុម ឬជាបុគ្គល។
- បន្ទាប់មកឱ្យសិស្សប្រកបព្យាង្គក្នុងសៀវភៅពុម្ពរៀងៗខ្លួនពី ក្តា ..... ក្មោះ។

ចំណាំ : ចំពោះព្យញ្ជនៈផ្សំជាមួយជើងផ្សេងទៀត គ្រូគប្បីធ្វើដូច ក ផ្សំនឹងជើង ◌្ប ដែរ។

សកម្មភាពទី៣៖ បង្ហាញពាក្យ

- លើករូបភាព ឬកឧទាហរណ៍បង្ហាញសិស្ស ដើម្បីបង្រៀនពាក្យក្បាល ... ឱ្យសិស្សប្រាប់ឈ្មោះរូបភាព។ គ្រូបង្ហាញប័ណ្ណពាក្យ និងអានពាក្យឱ្យសិស្សថាតាម។
- នាំសិស្សវិភាគពាក្យដោយសួរថា តើពាក្យ ក្បាល មានព្យញ្ជនៈអ្វីខ្លះ? គ្រូសរសេរពាក្យនៅលើក្តារខៀន។ ឧទាហរណ៍ ក្បាល = ក្ប ◌ា ល (ក្បាល មាន ក្ប ស្រៈ◌ា និង ល)
- នាំសិស្សផ្សំពាក្យ : ក្ប ◌ា ល → ក្បាល ។ នាំសិស្សអាន ក្ប ◌ា និង ល ក្បាល។

- សួរសិស្ស តើ ក្ប មានអក្សរអ្វីខ្លះ? (ក្ប មាន ក ជើង ្ប) ប្រាប់សិស្សថា ជើង ្ប ក៏មានសូរសំឡេងដូច ព្យញ្ជនៈ ប ដែរ។ ប្រាប់សិស្សថា ការអានព្យញ្ជនៈផ្ញើជើង គេត្រូវអានព្យញ្ជនៈខាងលើមុន ក ហើយផ្សំសូររបស់ ជើង ព្យញ្ជនៈខាងក្រោម ្ប ទៅជា ក្ប។
- ប្រកបពាក្យឱ្យសិស្សស្តាប់ ក ជើង ្ប ក្ប , ក្ប ា ល, → ក្បាល រួចឱ្យសិស្សអានជាក្រុម ជាបុគ្គល។
  ចំណាំ : ចំពោះពាក្យផ្សេងទៀត គ្រូគប្បីបង្រៀនដូច ពាក្យ ក្បាល ដែរ។

សកម្មភាពទី៤៖ បង្ហាញល្អៈ

សូមធ្វើតាមលំនាំបង្រៀនអាននិងសរសេរព្យញ្ជនផ្សំនឹងស្រៈ។

សកម្មភាពទី៥៖ ហ្វឹកហាត់អាននិងសរសេរ

- ហៅពាក្យឱ្យសិស្សចង្អុល និងចង្អុលពាក្យឱ្យសិស្សអាន
- ហៅសិស្សពូកែឱ្យឡើងអានព្យាង្គនិងពាក្យនៅក្តារខៀន រួចឱ្យសិស្សអានសៀវភៅតាមក្រុមតូចៗ
- ហៅពាក្យឱ្យសិស្សសរសេរនៅលើក្តារឆ្នួន។
- ហៅសិស្សសរសេរលើក្តារខៀន។

៩. បង្រៀនអាន សរសេរ និងប្រកប

☆ ឧទាហរណ៍ ៖ ប្រកបនឹង □ក □ក់ (២ម៉ោង)

សកម្មភាពទី១៖ ការបង្ហាញព្យាង្គ ឬពាក្យ

- បង្ហាញព្យញ្ជនៈចល័ត ក រួចសួរថា នេះជាព្យញ្ជនៈអ្វី? គ្រូយកព្យញ្ជនៈ ក មួយទៀតមកបង្ហាញរួចសួរដូចមុន។
- ដាក់ផ្ដឹមគ្នា ក ក រួចអាន ក និង ក កក ឱ្យសិស្សថាតាមម្តងម្នាក់ ជាក្រុម តូចៗ។ គ្រូសរសេរ កក លើក្តារខៀន។
- យកព្យញ្ជនៈ ខ មកដាក់ជាប់នឹងព្យញ្ជនៈ ក រួចឱ្យសិស្សអានថា ខ និង ក ខក រួចសរសេរពាក្យ ខក លើក្តារ ខៀន។
- យកព្យញ្ជនៈ ក មកដាក់ជាមួយ ក ឱ្យសិស្សអានម្តងទៀត រួចគ្រូដាក់សញ្ញាបន្តក់ពីលើក (តួប្រកប) ហើយនាំ សិស្សអាន ក និង ក កក បន្តក់មួយ កក់។ ខ និង ក ខក បន្តក់មួយ ខក់ ។ ប្រាប់សិស្សថាសញ្ញា (់) គេហៅថា បន្តក់។ (ចំពោះពាក្យមានន័យគ្រូគប្បីប្រើសម្ភារៈ រូបភាព កាយវិការ ដើម្បីឱ្យសិស្សយល់ន័យពាក្យ)។
- អានពាក្យដោយប្រកបឱ្យសិស្សស្តាប់និងថាតាម
- ឧទាហរណ៍ ក និង ក កក , ក និង ក កក បន្តក់មួយ កក់ . . .
- ឱ្យសិស្សអានកក **កក់ ខក ខក់** កាក កាក់ ផឹក...
- នាំសិស្សអានតាមសូរសំឡេងពួក [អ៊ិ]ដូចជាៈ
  - គ និង ក គក , ល និងក លក
  - គ និង ក គក បន្តក់មួយ គក់ ល និង ក លក បន្តក់មួយ លក់
  - គ អ៊ិ គា និង ក គាក គ អ៊ិ គា និង ក គាក បន្តក់មួយ គាក់
  - ល អ៊ិ លា និង ក លាក ល អ៊ិ លា និង ក លាក បន្តក់មួយ លាក់

សកម្មភាពទី២ ៣ ៤និង៥ សូមធ្វើតាមលំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈ។

១០. បង្រៀនអានលិខសរសេរព្យាង្គតម្រួត

↳ ឧទាហរណ៍ ៖ ព្យាង្គតម្រួត "ង្ក ង្ខ ង្គ ង្ឃ ង្ង ង្រ ង្ឋ ង្ស ង្ហ ង្ឡ" (២ម៉ោង)

សកម្មភាពទី១៖ បង្ហាញព្យាង្គតម្រួត

ក. ព្យាង្គតម្រួត ង្ក ង្ខ...

- ចម្លងចំណងជើងមេរៀន (ង្ក ង្ខ ...) ជាក់លើក្តារខៀន
- នាំសិស្សអានព្យាង្គតម្រួតដូចខាងក្រោម៖
- **ង្ក ង្ខ ង្គ** អានថា **ង** ជើង **ក, ង** ជើង **ខ, ង** ជើង **គ**... ។

សកម្មភាពទី២៖ បង្ហាញពាក្យ

- គ្រូបង្ហាញសម្ភារៈជាក់ស្តែង ឬរូបភាពដើម្បីបំផុសរកពាក្យ។
- គ្រូសរសេរវិធីបំបែកពាក្យនៅក្តារខៀន ឬលើផ្ទាំងក្រដាសតាមលំនាំខាងក្រោម ជាអក្សរធំៗ។

(គ្រូអាចប្រើពណ៌ក្រហម សម្រាប់បន្តក់ និងជើងព្យញ្ជនៈ)។

ឧទាហរណ៍ : **អង្ករ = អង់ ករ** ប្រាប់សិស្សថា **អង្ករ** ជាពាក្យពីរព្យាង្គដែលសរសេរត្រួតគ្នាឬហៅថាព្យាង្គតម្រួត។

- ព្យាង្គទី១ **អង់**
- ព្យាង្គទី២ **ករ**
- **អ** និង **ង** ត្រូវអានថា **អង់** ជើង ◌ ត្រូវអានដូចកដៃរ ជើង ◌ និង **រ** ត្រូវអានដូច **ក** និង **រ** គឺ **ក** ។ ដូចនេះ **អង្ករ** ត្រូវអានថា **អ** និង **ង** អង់ **ក** និង **រ ក អង្ករ** ។

- នាំសិស្សអានពាក្យព្យាង្គតម្រួត ដូចខាងក្រោម៖
  - **អ** និង **ង** អង់ **ក** និង **រ ករ អង្ករ**
  - **ក** និង **ងកង់ ក អែ កែ** និង **បកែប កង្កែប**
- ហៅសិស្សឡើងអានម្តងម្នាក់ ឬអានជាក្រុមតូចៗ។
- ហៅពាក្យឱ្យសិស្សធ្វើអក្ខរវិញ្ញាស និងសរសេរលើក្តារឆ្នួន។

ខ. ព្យាង្គតម្រួត ង្រ ញ្ច្រ ន្ត្រ ...

- ដឹកនាំអានដូចខាងក្រោម៖
  - **ង** ជើង **ក** ជើង **រ, ញ** ជើង **ច** ជើង **រ , ន** ជើង **ត** ជើង **រ**
  - **អង្ក្រង** អានថា **អ** និង **ង អង់ ក**ជើង **◌្រ ក្រ ក្រ** និង **ង ក្រង = អង្ក្រង** ។
  - **កន្ត្រែ** អានថា **ក** និង **ន កន់ ត** ជើង **◌្រ ត្រ ត្រ អែ ត្រែ = កន្ត្រែ** ។

សកម្មភាពទី៣ ៤និង៥ សូមធ្វើតាមលំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈ។

ព័ត៌មានជំនួយ

- ចំពោះខ្លឹមសារក្នុងសៀវភៅគប្បីបែងចែកពីរពេល(មួយពេលពីរម៉ោង)ឱ្យសមស្រប។ លើកទី១ ត្រូវបង្រៀនពាក្យ និងឈ្នះខ្លះៗ លើកទី២ត្រូវបង្រៀនពាក្យ ឬឈ្នះ (បើមាន) ដែលនៅសល់។
- គ្រប់មេរៀនបើមានពាក្យឬឃ្លាច្រើន គ្រូមិនត្រូវបង្រៀនទាំងអស់នោះទេ គឺដកយកតែពាក្យ ឬឃ្លាដែលសមស្របនឹងពេលវេលាមកបង្រៀន ឯពាក្យឬឃ្លានៅសល់ ត្រូវដាក់ជាកិច្ចការផ្ទះ ឬអំណានបន្ថែម។
- គ្រូអាចដូរ ឬថែមពាក្យខ្លះតាមការចាំបាច់ឱ្យតែពាក្យនោះផ្សំដោយព្យាង្គតម្រួតដែលត្រូវរៀន។

១១. បង្រៀនអំណាន

សកម្មភាពទី១៖ ទំនាក់ទំនង

- គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណងជើង
- សរសេរចំណងជើងដាក់នៅក្តារខៀន
- ឱ្យសិស្សអាននិងប៉ាន់ស្មានខ្លឹមសារមេរៀន
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន។

សកម្មភាពទី២៖ អំណានលើកទី១

- ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ
- ឱ្យសិស្សឡើងសរសេរពាក្យទាំងនោះនៅលើក្តារខៀន(បើមានអត្ថបទនៅលើក្តារខៀន អាចឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)
- ដឹកនាំសិស្សឱ្យយល់ន័យពាក្យពិបាក ដោយបង្ហាញរូបភាព ធ្វើកាយវិការ ប្រៀបធៀប ឬសំណួរបំផុស ឬប្រើបទានុក្រម

សកម្មភាពទី៣៖ អំណានលើកទី២

- ឱ្យសិស្សអានសំណួរដោយស្ងៀមស្ងាត់
- ឱ្យសិស្សអានអត្ថបទម្តងទៀតដោយស្ងៀមស្ងាត់ដើម្បីយល់ខ្លឹមសារមេរៀន
- សួរសំណួរឱ្យសិស្សឆ្លើយម្តងមួយៗ។បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញដោយស្ងៀមស្ងាត់ឬដោយឮៗដើម្បីយល់និងអាចឆ្លើយបាន។
- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ។

សកម្មភាពទី៤៖ អំណានលើកទី៣

- អានអត្ថបទជាគំរូឱ្យសិស្សស្តាប់និងថាតាមម្តងមួយឃ្លះៗរហូតចប់ដោយមានការអានតាមលំនាំផ្អាកនិងដាក់សំឡេងនៅពេលបញ្ចប់ឃ្លះនីមួយៗនិងនៅត្រង់ដកឃ្លា ដោយប្រាប់សិស្សថា កាលណាយើងដកឃ្លា គេត្រូវផ្អាកបន្តិច ទើបបន្តអានតទៅទៀត។ កាលបើឃើញសញ្ញាខណ្ឌ "។" ត្រូវដាក់សំឡេង ពីព្រោះវាបញ្ចប់ឃ្លះនីមួយ។ កាលបើឃើញសញ្ញាសួរ "?" ត្រូវលើកសំឡេងជាសំណួរ...។
- ឱ្យសិស្សពូកែម្នាក់អានឡើងវិញ
- ឱ្យសិស្សអានបណ្តាក់ជាបុគ្គលជាក្រុមឱ្យបានច្រើនដង ច្រើនសារ។
- លើកសរសើរក្រុមដែលអានបានល្អ។

១២. បង្រៀនអំណានបែបមេស្ងួត្រ

សកម្មភាពទី១៖ ទំនាក់ទំនង

- ប្រើសំណួរបំផុសផ្សេងៗទាក់ទងនឹងការសូត្រកំណាព្យ
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណងជើង

- សរសេរចំណងជើងមេសូត្រដាក់នៅក្តារខៀន រួចឱ្យសិស្សអាននិងប៉ាន់ស្មានខ្លឹមសារមេសូត្រ
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន។

សកម្មភាពទី២៖ សូត្រអត្ថបទលើកទី១

- ឱ្យសិស្សអានអត្ថបទមេសូត្រដោយស្ងៀមស្ងាត់ ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ
- ឱ្យសិស្សឡើងសរសេរពាក្យទាំងនោះនៅលើក្តារខៀន(បើមានអត្ថបទនៅលើក្តារខៀន អាចឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)
- ដឹកនាំសិស្សអានពាក្យពិបាក និងពន្យល់ន័យរបស់ពាក្យដោយប្រើរូបភាព លើកឧទាហរណ៍ ធ្វើការប្រៀបធៀបប្រើ បទានុក្រម ឬសំណួរបំផុស

សកម្មភាពទី២៖ សូត្រអត្ថបទលើកទី២

- ដឹកនាំសិស្សអានសំណួរត្រិះរិះ
- សូត្រឱ្យឮតាមបែបបទ នៃបទនីមួយៗជាគំរូ
- សូត្រអត្ថបទមេសូត្រម្តងមួយឃ្លាៗឱ្យច្បាស់ៗឱ្យសិស្សស្តាប់បន្ទាប់មកឱ្យសិស្សថាតាម ដើម្បីយល់ខ្លឹមសារ
- សួរសំណួរឱ្យសិស្សឆ្លើយម្តងមួយៗ។ បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សសូត្រត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញដោយស្ងៀមស្ងាត់ឬដោយឮៗដើម្បីយល់និងអាចឆ្លើយបាន។
- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ។

សកម្មភាពទី៣៖ សូត្រអត្ថបទលើកទី៣

- ឱ្យសិស្សដែលចេះធ្វើបទពិរោះ សូត្រឱ្យសិស្សដទៃទៀតស្តាប់
- ឱ្យសិស្សសូត្របណ្តាក់ជាបុគ្គលនិងជាក្រុមតូចៗ
- កែលម្អចំណុចខ្វះខាត

១៣. បង្រៀននិយាយ

សកម្មភាពទី១៖ ទំនាក់ទំនងមេរៀន

- សួរសំណួរបំផុសដើម្បីស្ទាបស្ទង់ចំណេះដឹងសិស្សដែលមានស្រាប់ដោយឱ្យសិស្សនិយាយ ឆ្លើយ ឬបង្ហាញពីអ្វីដែលពួកគេធ្លាប់ដឹងរួចមកហើយទាក់ទងនឹងមេរៀនថ្មី។

សកម្មភាពទី២៖ សន្ទនាលើកទី១

- ឱ្យសិស្សពិនិត្យរូបភាពក្នុងសៀវភៅ
- ឱ្យសិស្សនិយាយរូបភាពទៅតាមសំណួររបស់គ្រូ
- ឱ្យសិស្សស្វែងយល់ស្ថានភាពនិងតួអង្គនៅក្នុងបទសន្ទនា
- និយាយសម្តីបទសន្ទនាគំរូឱ្យសិស្សស្តាប់
- សួរសំណួរដើម្បីស្ទាបស្ទង់ការយល់ដឹងលើបទសន្ទនា និងសំនួនពាក្យចាំបាច់សម្រាប់ប្រើក្នុងបទសន្ទនានោះ
- និយាយសម្តីបទសន្ទនាគំរូឱ្យសិស្សថាតាម

សកម្មភាពទី៣៖ សន្ទនាលើកទី២

- ឱ្យសិស្សសន្ទនាតាមអត្ថបទគំរូនៅក្នុងក្រុម

- ដើរពិនិត្យនិងកែលម្អពីការលើកដាក់សំឡេង
- ឱ្យសិស្សឡើងសន្ទនាជាគូនៅមុខក្តារខៀន
- ឱ្យសិស្សហាត់និយាយឡើងវិញតាមលំនាំគំរូនៅក្នុងក្រុមដោយប្រើខ្លឹមសារផ្ទាល់ខ្លួនដោយលើកដាក់សំឡេង
- សម្របសម្រួលកែលម្អការនិយាយ និងកាយវិការរបស់សិស្ស។

ចំណាំ: ក្នុងករណីមិនមែនជាការសន្ទនា គ្រូគប្បីឱ្យសិស្សហាត់និយាយម្នាក់ឯង។

១៤. បង្រៀនស្តាប់

សកម្មភាពទី១៖ ការប្រើសំណួរបំផុស

- ឱ្យសិស្សឆ្លើយសំណួរបំផុសទាក់ទងពីអ្វីដែលពួកគេធ្លាប់ដឹង
- ឱ្យសិស្សអានចំណងជើងអត្ថបទ ចំណងជើងរឿង ពិនិត្យរូបភាព រួចឱ្យសិស្សប៉ាន់ស្មានខ្លឹមសាររឿង

សកម្មភាពទី២៖ និទានរឿង

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅ ឬសំណួរបិទលើក្តារខៀនជាមុន
- ប្រាប់សិស្សថានៅពេលគ្រូនិទានរឿងឱ្យស្តាប់ចប់កូនៗត្រូវឆ្លើយនឹងសំណួរទាំងអស់នេះ
- និទានរឿងឱ្យសិស្សស្តាប់ដោយយឺតៗនិងប្រើសម្លេងច្បាស់ៗព្រមទាំងបង្ហាញរូបភាពម្តងមួយផ្ទាំងៗតាមសាច់រឿង

សកម្មភាពទី៣៖ សួរសំណួរ

- សួរសំណួរឱ្យសិស្សឆ្លើយម្តងមួយៗ។ បើសិស្សឆ្លើយសំណួរណាមួយមិនបានគ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឡើងវិញដើម្បីឱ្យសិស្សស្តាប់ឡើងវិញ និងអាចឆ្លើយបាន
- សួរសំណួរថ្មីបន្ថែមផ្សារភ្ជាប់បទពិសោធដែលសិស្សរៀនរួចទៅនឹងបទពិសោធជាក់ស្តែង ដែលសិស្សជួបប្រទះក្នុងការរស់នៅ។

១៥. ជំនាំបង្រៀនសំណេរ

ក. ចំពេញល្បះនឹងពាក្យ

សកម្មភាពទី១៖ អាន...

- ឱ្យសិស្សបើកសៀវភៅ រួចឱ្យសិស្ស ២ ៣នាក់អាន
- ណែនាំបន្ថែមអំពីរបៀបធ្វើលំហាត់នោះ
- ឱ្យសិស្សអានល្បះទី១ រួចសួរ៖ តើអ្នកយល់ល្បះនេះឬទេ? តើអ្នកធ្វើដូចម្តេច ដើម្បីយល់ល្បះនេះ? (ចម្លើយ ត្រូវបំពេញពាក្យក្នុងចន្លោះល្បះ)
- ឱ្យសិស្សអានពាក្យក្នុងប្រអប់ ដើម្បីឱ្យដឹងថាត្រូវយកពាក្យណាមួយមកបំពេញឱ្យត្រូវន័យនិងរូបភាពនីមួយៗ
- ឱ្យសិស្សម្នាក់ឡើងសរសេរពាក្យនោះត្រង់ចន្លោះល្បះ រួចឱ្យអានល្បះនោះ
- ឱ្យសិស្សអានល្បះដែលបំពេញរួចបានត្រឹមត្រូវឡើងវិញជាបុគ្គលនិងជាក្រុមតូចៗ។

សកម្មភាពទី២៖ បំពេញ...

- ឱ្យសិស្សបំពេញល្បះដែលនៅសល់ តាមក្រុម ជាដៃគូ ឬម្នាក់ៗដាក់ក្នុងសៀវភៅ
- កំណត់រយៈពេល

- ឱ្យតំណាងក្រុមបង្ហាញចម្លើយ
- កំណែលម្អនិងកែដាក់ពិន្ទុ
- លើកសរសើរក្រុមដែលធ្វើបានល្អ
- ឱ្យសិស្សអានល្បះដែលបំពេញបានត្រឹមត្រូវឡើងវិញ រួចចម្លងល្បះដាក់ក្នុងសៀវភៅរៀងៗខ្លួន។

ខ. បំពេញល្បះតាមរូបភាព

សកម្មភាពទី១៖ អាន...

- ឱ្យសិស្សអានការណែនាំធ្វើលំហាត់ក្នុងសៀវភៅរួចសួរ៖ តើគេចង់ឱ្យធ្វើអ្វី? រួចណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់បើចាំបាច់
- ឱ្យសិស្សពិនិត្យរូបភាពទី១ រួចគ្រូសួរសំណួរដើម្បីឱ្យសិស្សយល់រូបភាពបានច្បាស់
- ឱ្យសិស្សហាត់បង្កើតល្បះផ្សេងៗដោយមាត់ទទេទាក់ទងនឹងរូបភាពទី១នោះ។
- កែលម្អខ្លឹមសារនិងឃ្លាល្បះឱ្យបានត្រឹមត្រូវ រួចឱ្យសិស្សសរសេរល្បះនោះលើក្តារខៀន
- ឱ្យសិស្សដទៃទៀតជួយកែអក្ខរាវិរុទ្ធ

សកម្មភាពទី២៖ បំពេញ...

- ឱ្យសិស្សបំពេញល្បះដែលនៅសល់ជាដៃគូ ឬក្រុមតូចដាក់ក្នុងសៀវភៅ ឬលើក្រដាស។
- កំណត់រយៈពេល
- ឱ្យតំណាងក្រុមបង្ហាញចម្លើយ
- កែលម្អកិច្ចការរបស់សិស្សនិងដាក់ពិន្ទុ
- លើកសរសើរក្រុមដែលធ្វើបានល្អ
- ឱ្យសិស្សអានល្បះដែលបំពេញបានត្រឹមត្រូវឡើងវិញ រួចចម្លងល្បះដាក់ក្នុងសៀវភៅរៀងៗខ្លួន។

១៦. បង្រៀនវេយ្យាករណ៍

សកម្មភាពទី១៖ ទំនាក់ទំនង

- បង្ហាញសម្ភារៈដាក់ស្តែង រូបភាព ឬធ្វើកាយវិការមួយចំនួនដែលទាក់ទងនឹងឧទាហរណ៍
- ឱ្យសិស្សសាកល្បងរកពាក្យតាមឧទាហរណ៍ខាងលើ

សកម្មភាពទី២៖ ការសិក្សាឧទាហរណ៍

- ឱ្យសិស្សមើលរូបភាពនៅផ្នែកខាងលើនិងអានពាក្យពីខាងក្រោមរូបភាពទាំងនោះ(អានស្ងាត់)
- សួរបំផុសទៅលើរូបម្តងមួយៗ រហូតដល់បានចម្លើយជាពាក្យដែលត្រូវរៀន ។

សកម្មភាពទី៣៖ ទាញយកបញ្ញត្តិ

- ប្រើសំណួរបំផុសបន្ថែមទៀត ដើម្បីឱ្យសិស្សប្រាប់បានបញ្ញត្តិ
- ឱ្យសិស្សអានបញ្ញត្តិ ២ ឬ៣នាក់។

១៧. បង្រៀនសរសេរតាមអាន

ក. សរសេរតាមអានចម្លង (១ម៉ោង)

សកម្មភាពទី១៖ បង្ហាញពាក្យ

- សរសេរឬបិទពាក្យមួយចំនួននៅលើក្តារខៀន

សកម្មភាពទី២៖ អានពាក្យ

- អានពាក្យម្តងមួយៗឱ្យច្បាស់ៗហើយឱ្យសិស្ស ២-៣នាក់ ឡើងចង្អុលពាក្យនីមួយៗអានតាម។
- ចង្អុលពាក្យទី១ និងអានម្តងទៀត។
- ឱ្យសិស្សធ្វើអក្ខរវិញ្ញាសពាក្យនោះ រួចឱ្យសិស្សសរសេរនៅលើក្តារឆ្នួនទាំងអស់គ្នា។
- ត្រួតពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យត្រូវឡើងវិញ។
- ចង្អុលពាក្យទី២ ទី៣ ...រហូតគ្រប់ពាក្យ ហើយធ្វើតាមលំនាំពាក្យបង្រៀនទី១ដែរ។

សកម្មភាពទី៣៖ សរសេរពាក្យក្នុងសៀវភៅ

- ហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ។
- ហៅពាក្យឡើងវិញឱ្យសិស្សផ្ទៀង
- ទុកពេលឱ្យសិស្សត្រួតពិនិត្យនិងកែកំហុស
- ឱ្យសិស្សប្តូរគ្នាកែដោយផ្ទៀងជាមួយពាក្យនៅលើក្តារខៀន
- ប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ។

ខ. សរសេរតាមអានរៀបចំ (១ម៉ោង)

សកម្មភាពទី១៖ បង្ហាញអត្ថបទ

- ចម្លងឬបិទពាក្យ ឃ្លា ល្បះ ឬអត្ថបទដាក់លើក្តារខៀន
- អានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម
- អានអត្ថបទដោយយឺតៗច្បាស់ៗ រួចឱ្យសិស្ស២ ឬ ៣នាក់អានឡើងវិញ។

សកម្មភាពទី២៖ អានពាក្យពិបាកក្នុងអត្ថបទ

- អានពាក្យនេះម្តងមួយៗ ឱ្យច្បាស់ៗឱ្យសិស្សចង្អុលពាក្យ និងអានតាម ២-៣នាក់
- អានពាក្យទាំងនោះដោយចង្អុលផង រួចឱ្យសិស្សធ្វើអក្ខរវិញ្ញាសនិងឱ្យសរសេរលើក្តារឆ្នួនទាំងអស់គ្នា
- ពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យបានត្រូវឡើងវិញ
- បន្តទៅពាក្យទី២ ទី៣រហូតដល់ចប់ដោយធ្វើតាមលំនាំបង្រៀនពាក្យទី១ដែរ។

សកម្មភាពទី៣៖ សរសេរអត្ថបទដាក់ក្នុងសៀវភៅ

- លាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅមួយឃ្លាម្តងៗ រហូតដល់ចប់
- អានអត្ថបទឡើងវិញឱ្យសិស្សស្តាប់និងផ្ទៀងឡើងវិញ
- ទុកពេលឱ្យសិស្សពិនិត្យ និងកែកំហុសរៀងៗខ្លួន
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន
- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ។

គ. សរសេរតាមអានត្រួតពិនិត្យ (១ម៉ោង)

សកម្មភាពទី១៖ អាន...

- អានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទខ្លីៗដែលតម្រូវឱ្យសិស្សសរសេរ។

- ឱ្យសិស្សទាំងអស់ស្តាប់ ដោយអានឱ្យឮនិងច្បាស់ៗ។

សកម្មភាពទី២៖ សរសេរក្នុងសៀវភៅ

- អាន (ហៅ) ពាក្យ កន្សោមពាក្យ ឬឃ្លាខ្លីៗ បីដងឱ្យសិស្សសរសេរតាម ម្តងមួយៗ រហូតដល់ចប់។
- អានឱ្យសិស្ស២នាក់ថាតាមក្រោយពីគ្រូអាន សិស្សទាំងអស់សរសេរ ដោយសិស្សម្នាក់ថាមុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថា ពីក្រោយបន្ទាប់ពីខ្លួនសរសេររួច
- អានឱ្យសិស្សស្តាប់ឡើងវិញដោយយឺតៗនិងច្បាស់ៗ ដើម្បីឱ្យសិស្សធ្វើងផ្ទាត់និងកែតម្រូវពាក្យឬកន្សោមពាក្យ ដែលគេសរសេរលើងឬខុស
- ទុកពេលសមល្មមឱ្យសិស្សកែនិងបំពេញបន្ថែម
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន
- កំណត់កំហុសដែលត្រូវដក(ខុស១ដកកន្លះ ឬខុស២ដកកន្លះ)
- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ។

ចំណា : ចំពោះការសរសេរតាមអានត្រួតពិនិត្យ លោកគ្រូ អ្នកគ្រូអាចអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ផ្នែកទី៤
សណាគប័ត្រជំពូកនិងមេរៀន

ជំពូកទី១

ព្យញ្ជនៈពួក«អ»

រយៈពេល	31ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	ស្តាប់៖ ចម្រៀងអក្ខរក្រម
មេរៀនទី២	អាននិងសរសេរ៖ ក ត
មេរៀនទី៣	អាននិងសរសេរ៖ ច ធ
មេរៀនទី៤	រៀនសាឡើងវិញ៖ ក ត ច ធ
មេរៀនទី៥	និយាយ៖ ប្រាប់ឈ្មោះអាយុ ថ្នាក់រៀន និងវត្តនៅក្នុងថ្នាក់
មេរៀនទី៦	អាននិងសរសេរ៖ ដ ផ
មេរៀនទី៧	អាននិងសរសេរ៖ ប ថ
មេរៀនទី៨	និយាយ៖ ការណែនាំមិត្តភក្តិឱ្យស្គាល់គ្នា
មេរៀនទី៩	អាននិងសរសេរ៖ ខ
មេរៀនទី១០	រៀនសាឡើងវិញ
មេរៀនទី១១	ស្តាប់៖ រឿង រៃនិងស្រមោច
មេរៀនទី១២	និយាយ៖ សមាជិកគ្រួសារខ្ញុំ
មេរៀនទី១៣	អាននិងសរសេរ៖ ប ហ
មេរៀនទី១៤	អាននិងសរសេរ៖ ស ណ
មេរៀនទី១៥	អាននិងសរសេរ៖ ឡ អ
មេរៀនទី១៦	ស្តាប់៖ មេសូត្រ (បទកាកគតិ)
មេរៀនទី១៧	រៀនសាឡើងវិញ

មេរៀនទី១	**ស្តាប់៖ ចម្រៀងអក្ខរក្រម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីតួអក្សរនៅវគ្គណាមួយបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទ4 ដល់ទី5
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ27
កំណែលំហាត់	**លំហាត់ទី1**៖ ៤វគ្គ

	លំហាត់ទី2៖ សូរ ត នៅវគ្គទី៤ សូរ ច នៅវគ្គទី២

មេរៀនទី២	**អាននិងសរសេរ៖ ក ត**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជន: "ក ត" បានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី6ដល់ទំព័រទី7 **រូបភាព៖** កា ក តា ការ កែវ កាកអំពៅ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. កា ខ. ការ គ. កាត ឃ. កាក ង. កក(រ) ច. តិច **លំហាត់ទី2៖** កត កត ក **លំហាត់ទី3៖** ក ⇨ ការ ខ ⇨ កី គ ⇨ កា ឃ ⇨ កាក ង ⇨ តាតី ច ⇨ ककर

មេរៀនទី៣	**អាននិងសរសេរ៖ ច ឆ**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជន: "ច ឆ" បានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី8ដល់ទំព័រទី9 **រូបភាព៖** ព ឆា ចាប ចក ចចក ចឹក ចេក ចឹក រូបតាឆក រូបឆុងតែ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. ចាប ខ. ចចក គ. ចក **លំហាត់ទី2៖** ក. ឆក ខ. ឆុង គ. ចក **លំហាត់ទី3៖** ក. ចក ខ. ចចក គ. ឆុង **លំហាត់ទី4៖** ចឆ ឆច ឆច

មេរៀនទី៤	**រៀនសាឡើងវិញ**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជន: "ក ត ច ឆ" បាន ត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី10ដល់ទំព័រទី11 **រូបភាព៖** ទំព័រទី 10 – 11
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ណែលំហាត់	**លំហាត់ទី1៖** ក. កាក កា ककर कर ត. តិច តាតី ច. ចឹក ចូក ចចក ឆ. ឆុង ឆា ឆក **លំហាត់ទី2៖** ក. តាតីចូកចក។ ខ. តាឆាំឆុងតែ។ **លំហាត់ទី3៖** (ចម្លើយដាក់ស្តែង)

មេរៀនទី៥	**និយាយ៖ ប្រាប់ឈ្មោះ អាយុ ថ្នាក់រៀន និង វត្តនៅក្នុងថ្នាក់**
រយៈពេល	1 ម៉ោ
វត្ថុបំណង	ណែនាំខ្លួន និង ថ្នាក់រៀនទៅកាន់នរណាម្នាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី12ដល់ទំព័រទី13 **រូបភាព៖** ក្មេងស្រីនិងក្មេងប្រុសឈរនិយាយគ្នា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. ខ្ញុំឈ្មោះ ធីតា។ ខ. អាយុ 8ឆ្នាំ ។ គ. ថ្នាក់ទី1 នៃសាលាបឋមសិក្សា ដើម្បីភាពញញឹមនៃកុមារ។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៦	**អាននិងសរសេរ៖ ដ ផ**
រយៈពេល	2 ម៉ោ
វត្ថុបំណង	អាននិងសរសេពាក្យផ្សំពីព្យញ្ជន: "ដ ផ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី13ទំព័រទី14 **រូបភាព៖** ដៃ ផែ ដក ដូរ កាដា កៀរដី កដៃ ដើរ ដឹកជើ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. ផែ ខ. ដៃ **លំហាត់ទី2៖** ក. កដៃ ខ. ដឹកជើ គ. កៀ(រ)ដី **លំហាត់ទី3៖** ក. ផឹកតែ ខ. កាដា គ. ដើរ

មេរៀនទី៧	**អាននិងសរសេរ៖ ប ថ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេពាក្យផ្សំពីព្យញ្ជាន: "ប ថ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី15 **រូបភាព៖** ហានីយ ថូ ថត
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់៖** ក. ថូ ខ. ថត គ. ហានីយ

មេរៀនទី៨	**និយាយ៖ ការណែនាំមិត្តភក្តិឱ្យស្គាល់គ្នា**
រយៈពេល	1 ម៉ោ
វត្ថុបំណង	ណែនាំមិត្តម្នាក់ឱ្យមិត្តម្នាក់ទៀតស្គាល់បានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី16ដល់ទំព័រទី17 **រូបភាព៖** ក្មេងប្រុសពីរនាក់ស្រីម្នាក់ឈរនិយាយគ្នា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៩	**អាននិងសរសេរ៖ ខ**
រយៈពេល	2 ម៉
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជនៈ "ខ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី17ដល់ទំព័រទី18 **រូបភាព៖** លោកខែ ខោ តាខេ ខែ ខួរ តាដេញតាខេ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. ខែ ខ. ខែ គ. ខោ ឃ. តាខេ **លំហាត់ទី2៖** ក. ខោ ខ. ខែ គ. តាខេ ឃ. ខែ **លំហាត់ទី3៖** ក. តាខេ ខ. ខឹង គ. តាខា ឃ. ខាំ ង. ខ៖

មេរៀនទី១០	**ស្តាប់៖ រឿង រៃនិងស្រមោច**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីព្រឹត្តិការណ៍នៅក្នុងអត្ថបទរឿងនិទានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី19ដល់ទំព័រ20 **រូបភាព៖** រៃនិងស្រមោច
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ27
ចម្លើយសំណួរ	1. ស្រមោច រៃ និងដើមឈើ។ 2. ស្រមោចកំពុងរកចំណី។
កំណែលំហាត់	**លំហាត់ទី1៖** ក.1 ខ.4 គ.2 ឃ.3 **លំហាត់ទី2៖** សម្តីរៃល្អ៖ ខ សម្តីស្រមោចល្អ៖ ក គ ឃ **លំហាត់ទី3៖** ក. ឧស្សាហ៍ព្យាយាម ខ. សប្បាយភ្លើតភ្លើន

មេរៀនទី១១	**រៀនសាឡើងវិញ**
រយៈពេល	2 ម៉
វត្ថុបំណង	ប្រាប់ស្រៈនិងព្យញ្ជនៈដែលត្រូវយកមកបំពេញតាមចន្លោះនីមួយៗបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី21ដល់ទំព័រ22

	រូបភាព៖ ដើរ ដេរ ផែ កៀរដី ហានីយ ខោ ថៃតាខេ ថតរូប
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. ខោ ខ. កៀ(រ)ដី **លំហាត់ទី2៖** ក. តាផែកៀ(រ)ដី។ ខ. ចៅកែដើរ។ **លំហាត់ទី3៖** ក. កៀ(រ)ដី ខ. ថើប

មេរៀនទី១២	**និយាយ៖ សមាជិកគ្រួសារខ្ញុំ**
រយៈពេល	1ម៉ោ
វត្ថុបំណង	ណែនាំសមាជិកគ្រួសារនិងខ្លួនឯងទៅកាន់អ្នកណាម្នាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី23 **រូបភាព៖** ក្មេងស្រី ក្មេងប្រុស
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី១៣	**អាននិងសរសេរ៖ ប ហ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ "ប ហ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី24ដល់ទំព័រទី25 **រូបភាព៖** បបែល ហង្ស បីចៅ បំបៅ បៀ ហា ហើរ ហិប បបរហៀរ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. ហា ខ. ហៀរ គ. បី **លំហាត់ទី2៖** ក. ហិប ខ. បំបៅ **លំហាត់ទី3៖** ខ. ចៅហំខំដំដែក។

មេរៀនទី១៤	**អាននិងសរសេរ៖ ស ណ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជនៈ "ស ណ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី26ដល់ទំព័រទី27 **រូបភាព៖** សី រណា សោ សេក
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. សី ខ. ដំណាំ គ. សេក **លំហាត់ទី2៖**

	ក. បូណាថែដំណាំ។ ខ. ចៅសៅខាំដៃតាបូ។ គ. សូណាដាំតែ។ ឃ. តាសីសរសើរសីហា។ **លំហាត់ទី3៖** ក. ខះក ខ. ស(រ)សេ(រ) គ. សីហា ឃ. សសៀរ

មេរៀនទី១៥	**អាននិងសរសេរ៖ ឡ អ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ "ឡ អ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី28ដល់ទំព័រទី29 **រូបភាព៖** ឡ អំបោះ អារ កៅអី កីឡា ឡាន អាកោ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. អាហារ ខ. អំបោះ គ. កៅអី ឃ. អាកោ **លំហាត់ទី2៖** កីឡា ឡាន អាកោ

មេរៀនទី១៦	**ស្តាប់៖ មេសូត្រ បទកាកគតិ**
រយៈពេល	2ម៉ោ
វត្ថុបំណង	សូត្របទកាកគតិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី30 **រូបភាព៖** ទំព័រ30
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ27
ចម្លើយសំណួរ	1. ពុកម៉ែបានធ្វើការបីបាច់ថែរក្សា ចិញ្ចឹម ថ្នាក់ថ្នម... 2. លោកខំតស៊ូនឹងការលំបាកដើម្បីកូន។ 3. កូនៗត្រូវខិតខំរៀនសូត្រ ស្តាប់ដំបូន្មាន .....
កំណែលំហាត់	**លំហាត់៖** (១) គុណ (២) ធ្ងន់ (៣) សុខសាន្ត (៤) ប៉ុន្មាន

មេរៀនទី១៧	**រៀនសាឡើងវិញ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជនៈ"ប ហ ស ណ ឡ អ" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី31ដល់ទំព័រទី32 **រូបភាព៖** សត្វហើរ ចៅដោះ សោ អាហារ សំឡី សេក កៅអី អំបោះ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ19
កំណែលំហាត់	**លំហាត់ទី1៖** ក. សរសេរ ខ. បោះសី គ. ថែដំណាំ

លំហាត់ទី2៖ កុមារបោះបាល់។ ចៅឡាំដើរឡែឡឡ។ សុខាដេរខោ។
លំហាត់ទី3៖ ក. បោះ ខ. ឡែឡឡ គ. តាឡាំ ឃ. កៅអី

ជំពូកទី២

ព្យញ្ជនៈពួក«អ៊»

រយៈពេល	27ម៉ោ
ចំណងជើងសមត្ថភាព	
មេរៀនទី១	អាននិងសរសេរៈ គ ក
មេរៀនទី២	អាននិងសរសេរៈ ជ ង ធ
មេរៀនទី៣	អាននិងសរសេរៈ ព ញ
មេរៀនទី៤	ស្តាប់ៈ រឿង ក្អែកមានគំនិត
មេរៀនទី៥	រៀនសាឡើងវិញ
មេរៀនទី៦	និយាយៈ ប្រាប់ព័ត៌មានពីឪពុក ម្តាយ ឬអាណាព្យាបាល
មេរៀនទី៧	អាននិងសរសេរៈ ឃ ឈ យ ល
មេរៀនទី៨	អាននិងសរសេរៈ ឣ ឍ ទ ន
មេរៀនទី៩	អាននិងសរសេរៈ ម រ វ
មេរៀនទី១០	វេយ្យាករណ៍ៈ ខ្ញុំ ឯង គេ យើង
មេរៀនទី១១	ស្តាប់ៈ រឿង កូនទន្សាយទៅសាលារៀន
មេរៀនទី១២	រៀនសាឡើងវិញ

មេរៀនទី១	**អាននិងសរសេរៈ គ ក**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ «គ ក»បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី34ដល់ទំព័រ35 **រូបភាពៈ** ផ្លែគ កេ សាគរ សាគូ ស្គរសំភោរ កំភែម
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1ៈ** កេ ⇨ គ គោ ⇨ គ អគារ ⇨ គ **លំហាត់ទី2ៈ** ក. សុភាពគួរកេ។ ខ. តាគាថៃគោបា។ **លំហាត់ទី3ៈ** គារ អគារ គគីរ គេ គោ គោៈ សំភោ(រ) កំភែម ។

មេរៀនទី២	**អាននិងសរសេរៈ ជ ង ធ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពី ព្យញ្ជនៈ «ជ ង ធ»បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី36ដល់ទំព័រទី37 **រូបភាពៈ** ជីរ ងារ ធូប ជើង ងូត
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1ៈ** ងារ ធារ ភា **លំហាត់ទី2ៈ** ជំរំ ធំ ជំងឺ ធូរធារ **លំហាត់ទី3ៈ** ក. ជើង ខ. ជិៈ **លំហាត់ទី4ៈ** (ចម្លើយជាក់ស្តែង) ជើង ជជុៈ ងារ ងាក ធំ ធូរ

មេរៀនទី៣	**អាននិងសរសេរៈ ព ញ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ «ព ញ» បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី38ដល់ទំព័រ39 **រូបភាពៈ** ចំពុៈ សំពៈ ពូថៅ សំពៅ ពពែ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1ៈ** ក. សំពៅ ខ. គោញី គ. អំពៅ ឃ. ពួរ ង. ញញួរ ច. ពពែ ឆ. ពូថៅ ជ. ផ្លែញ **លំហាត់ទី2ៈ** ក. ជីតាខំពបូណា។ ខ. តាជាមានពពែញីពីរ។

មេរៀនទី៤	**ស្តាប់ៈ រឿង ក្អែកមានគំនិត**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប៉ាន់ស្មានហេតុការណ៍នៃរឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.សទំព័រទី40 **រូបភាពៈ** សត្វក្អែក ក្អម
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ27
ចម្លើយសំណួរ	1. បានជាក្អែកស្រែកខ្វកៗវារកទឹកផឹក។ 2. ក្អែករកឃើញទឹកនៅក្នុងក្អម។ 3. ក្អែកផឹកទឹកបានដោយពាំគ្រាប់ក្រួសទៅដាក់ក្នុងក្អម។
កំណែលំហាត់	**លំហាត់ទី1ៈ** ក. ជាសត្វមានគំនិតនិងព្យាយាមតស៊ូ។ **លំហាត់ទី2ៈ** (ចម្លើយជាក់ស្តែង)

មេរៀនទី៥	**រៀនសារឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អានពាក្យផ្សំពីព្យញ្ជនៈ «គ ក ជ ង ធ» ដោយមានរូបភាពជាជំនួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី41ដល់ទំព័រទី42 **រូបភាព៖** ជីរ ងាវ ធូប ដើង ងូត គោ កេ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1៖** ក. គោបា ខ. កេ គ. ជីរ ឃ. ងាវ ង. ធូប ច. ញញួរ ឆ. ពពែ ជ. អគារ **លំហាត់ទី2៖** ក. ចៅងីចេះងរ។ ខ. ពូជាជិះសេះ។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. អាត្មោតឈរយ៉ាងសង្ហា។ ខ. កេញីដើរកចំណី។

មេរៀនទី៦៖	**និយាយ៖ ប្រាប់ព័ត៌មានពីឪពុក ម្តាយ ឬអាណាព្យាបាល**
រយៈពេល	2ម៉ោ
វត្ថុបំណង	និយាយពីចំណង់ចំណូលចិត្តនិងគោលបំណងរបស់ឪពុកម្តាយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី43ដល់ទំព័រទី44 **រូបភាព៖** ជាងកាត់ដេរ គ្រូពេទ្យ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) តួអង្គ ឈ្មោះឪពុកនិងមុខរបរ ឈ្មោះម្តាយនិងមុខរបរ សំ សៃមជានគរបាល ចរិយាជាជាងកាត់ដេរ បូផា វិសាលជាគ្រូពេទ្យ និមលជាគ្រូបង្រៀន **លំហាត់ទី2៖** (១) កុសល (២) គ្រូពេទ្យ (៣) ធីតា (៤) គ្រូពេទ្យ (៥) ជាងកាត់ដេរ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៧	**អាននិងសរសេរ៖ យ ឈ យ ល**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ «យ ឈ យ ល» បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី45ដល់ទំព័រទី46 **រូបភាព៖** ឈរ យំ លា មេឃុំ ឈូក ឈើ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1៖** យីហោ មេឃុំ យោរយៅ យាយី សាលាឃុំ **លំហាត់ទី2៖** ក. ឃរ ខ. លលក

	លំហាត់ទី3៖ ក. លា ខ. យោធា គ. លលក ឃ. ឈរ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. តាឈើឈីដៃបីខែ។ ខ. លាឈរ។ គ. ពូឈុំលីឈើ។ ឃ. តាឌុំដើរសំដៅទៅសាលាឃុំ។

មេរៀនទី៨	**អាននិងសរសេរ៖ ឝ ឍ ទ ន**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជន: «ឝ ឍ ទ ន» បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី47ដល់ទំព័រទី48 **រូបភាព៖** ឈមរា ទា ទទូរ នៅនាង ទទា នាឡិកា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1៖** ក. ទា ខ. ទូ គ. នាឡិកា ឃ. ឈមរា **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) ទទឹង ទួល នៅនាង រនោច **លំហាត់ទី3៖** ក. ទំ ខ. គំនូរ គ. ដើរ **លំហាត់ទី4៖** ក. ឪណាដើរ ⇨ ទៅសាលា។ ខ. នារី ⇨ បេះនៅនាង។ គ. នេះជាសត្វ ⇨ ឆ្មាមរា។ ឃ. តាឪ ⇨ បេះទទឹម ។

មេរៀនទី៩	**អាននិងសរសេរ៖ ម រ វ**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជន: «ម រ វ»បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី49ដល់ទំព័រទី50 **រូបភាព៖** មូរ មី រៃ រាំ វារ វះ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1៖** ក. រាំ ខ. មាន់ គ. មូស ឃ. រៃ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) រុយ រឹង រឹង រាយ មឹង មមាច មមី មមែ វាយ រវៃ ររើរវាយ វិហារ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

	ក. វាសនាឈរមើលព្រះចន្ទនិងផ្កាយ។ ខ. តាយីដើរសំដៅទៅព្រះវិហារ។

មេរៀនទី១០	**វេយ្យាករណ៍៖ ខ្ញុំ ឯង គេ យើង**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់ពាក្យ "ខ្ញុំ ឯង គេ យើង" បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី51 **រូបភាព៖** ទំព័រ51
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ28
កំណែលំហាត់	**លំហាត់ទី1៖** 1. ខ្ញុំ 2. ឯង 3. យើង **លំហាត់ទី2៖** 1. ខ្ញុំ 2. ឯង 3. គេ 4. យើង

មេរៀនទី១១	**ស្តាប់៖ រឿង កូនទន្សាយទៅសាលារៀន**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាផ្នែកណាមួយនៃរឿងតាមរយៈរូបភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី52ដល់ទំព័រទី53 **រូបភាព៖** កូនទន្សាយទៅសាលារៀន
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ27
ចម្លើយសំណួរ	1. កូនទន្សាយឈ្មោះទីណូ។ 2. កូនទន្សាយទៅសាលារៀនទាន់ពេល។ 3. បានជាកូនស្វាមករៀនយឺតព្រោះរកសៀវភៅ។
កំណែលំហាត់	**លំហាត់ទី1៖** គ. នាឡិការោទ៍ខ្លាំងរឹងៗ។ **លំហាត់ទី2៖** ក. 3 ខ. 2 គ. 1 ឃ. 4 **លំហាត់ទី3៖** ខ្ញុំមិនគួរយកតម្រាប់តាមកូនស្វាទេ ពីព្រោះស្វាជាសិស្សគ្មានសណ្តាប់ធ្នាប់ល្អ។

មេរៀនទី១២	**រៀនសាឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈ «ឧ ឈ ទ ន» បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី54ដល់ទំព័រទី55 **រូបភាព៖** ឧប ឈមរ ទទា នាឡិកា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ20
កំណែលំហាត់	**លំហាត់ទី1៖** ក. ឧប ខ. រទេះគោ គ. នាឡិកា ឃ. ទទូរ **លំហាត់ទី2៖** ក ⇨ឈូឆរ ខ ⇨សេះឈើ គ ⇨លាជីតា ឃ ⇨យំយូរ

លំហាត់ទី3៖ ក. ជើងពីរ ខ. រទេះគោ

លំហាត់ទី4៖ (ចម្លើយជាក់ស្តែង)

ឃុំ យោរយៅ ឃូរៗ មេឃុំ យៈ យិនធាយ

ឈឺ ឈើ ឈូស ឈរ ឈាម ឈម

លើ លា លាំ លូ លលក លង

នំ ននោង នាង នាម នោម នាទី

រី រាំ រាប រឹង រីក រឹង

ជំពូកទី៣

ង ញ ប ម យ រ វ ច ស ហ អ

រយៈពេល	15ម៉
ចំណងជើងសមត្ថភាព	
មេរៀនទី១	និយាយ៖ ប្រាប់ទីតាំងមនុស្ស សត្វ វត្ថុ និងទីកន្លែង
មេរៀនទី២	អាននិងសរសេរ៖ «ង ញ ប ម យ រ វ»
មេរៀនទី៣	អាននិងសរសេរ៖ «ប ស ហ អ»
មេរៀនទី៤	វេយ្យាករណ៍៖ របស់ខ្ញុំ របស់ឯង របស់វា របស់យើង របស់គេ
មេរៀនទី៥	ស្តាប់៖ រឿង ខ្លានិងកេពីរ
មេរៀនទី៦	រៀនសាឡើងវិញ៖

មេរៀនទី១	**និយាយ៖ ប្រាប់ទីតាំងមនុស្ស សត្វ វត្ថុ និងទីកន្លែង**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ទីតាំងមនុស្ស សត្វ វត្ថុ និងទីកន្លែងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី57 **រូបភាព៖** សាលារៀន ថ្នាក់រៀន ក្នុង ក្រៅ លើ ក្រោម
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** សាលារៀននៅជាប់ផ្លូវធំ , មណ្ឌលសុខភាពនៅជិតសាលារៀនរំលងមួយផ្លូវ , សាលាឃុំនៅក្រោយសាលារៀនរំលងមួយផ្លូវ ,វត្តនៅក្រោយសាលាឃុំរំលងមួយផ្លូវ

មេរៀនទី២	**អាននិងសរសេរ៖ « ង ញ ប ម យ រ វ »**
រយៈពេល	4ម៉
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពី « ង ញ ប ម យ រ វ » បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី58ដល់ទំព័រទី59 **រូបភាព៖** កូនង៉ា ម៉ូតូ ចាប៊ី ផ្កាចំប៉ា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ក. ម៉ូតូ ខ. ចាប៊ី **លំហាត់ទី2៖** ម៉ៅ ហោប៉ៅ ញ៉ែះញ៉ោះ តារ៉ៅ ទូ រណារ៉

	លំហាត់ទី3៖ ពូសុខាឈឺពុំរ៉ៃនៅលើគ្រែ។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) កូនង៉ា ញុំ ប៉ាហ៊ី ម៉ែ អាយ៉ៃ ពុំរ៉ៃ រ៉ែនតា

មេរៀនទី៣	**អាននិងសរសេរ៖ « ប៊ សិ ហ៊ិ អ៊ »**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពី« ប៊ សិ ហ៊ិ អ៊ » បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី60ដល់ទំព័រទី61 **រូបភាព៖** សាប៊ូ តៅហ៊ូ កៅស៊ូ ទ្រអ៊ូ ហ៊ឹង
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** គ. សាប៊ូ **លំហាត់ទី2៖** ក. ទីនេះអ៊ូអរ។ ខ. កុមារតស៊ូទៅសាលា។ **លំហាត់ទី3៖** រអ៊ូ រយ៉ៃ តវ៉ា ទ្រអ៊ូ

មេរៀនទី៤	**វេយ្យាករណ៍៖ របស់ខ្ញុំ របស់ឯង របស់វា របស់យើង របស់គេ**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើពាក្យ ″ របស់ខ្ញុំ របស់ឯង របស់វា របស់យើង របស់គេ ″ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រទី62ដល់ទំព័រទី63 **រូបភាព៖** ទំព័រ62
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ28
កំណែលំហាត់	**លំហាត់ទី1៖** ក. របស់ឯង ខ. របស់ខ្ញុំ គ. របស់គេ ឃ. របស់យើង **លំហាត់ទី2៖** ក. របស់ខ្ញុំ ខ. របស់ឯង គ. របស់វា ឃ. របស់យើង របស់គេ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) នេះជាបិករបស់ឯងមែនឬទេ? កាតាបនេះជារបស់ខ្ញុំ។ នេះជាអាវរបស់វា។ នេះជាថ្នាក់រៀនរបស់យើង។ កុំយកសៀវភៅរបស់គេ។

មេរៀនទី៥	**ស្តាប់៖ រឿង ខ្លានិងកេពីរ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់សេចក្តីលម្អិតក្នុងអត្ថបទរឿងនិទានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី64ដល់ទំព័រទី65

	រូបភាព៖ ទំព័រទី 64 – 65
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ27
ចម្លើយសំណួរ	1. កេទាំងពីរចាប់បានត្រី នៅក្នុងបឹង។ 2. អ្នកបែងចែកចំណែកឱ្យកេគឺខ្លា 3. កេទាំងពីរទទួលចំណែកមិនស្មើគ្នាទេ ព្រោះកេចាញ់បោកខ្លា។
ណែលំហាត់	**លំហាត់ទី1៖** ក. 2 ខ. 3 គ. 1 **លំហាត់ទី2៖** ក. តួអង្គ2 ខ. មិនពេញចិត្ត

មេរៀនទី៦	**រៀនសាឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពី«ង់ ញ់ ប៉ ម៉ យ៉ រ៉ រ៉ៃ ប៊ ស៊ ហ៊ អ៊ » បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី66ដល់ទំព័រទី68 **រូបភាព៖** សាប៊ូ តៅហ៊ូ កៅស៊ូ ទ្រអ៊ូ ហ៊ឹងកូនង៉ា ម៉ូតូ ចាប៊ី ផ្កាចំប៉ា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** រ៉ុំរ៉ៃ សាប៊ូ ញ៉ែះញ៉ោះ តៅហ៊ូ **លំហាត់ទី2៖** ក. អាយ៉ៃ ខ. ឆែយ៉ាំ គ. តៅហ៊ូ ឃ. ម៉ែ ង. ម៉ូតូ ច. ចាប៊ី **លំហាត់ទី3៖** ក. ពូម៉ៅកេះ ⇨ ចាប៊ី។ ខ. ម៉ែសារីប៉ះ ⇨ ហោប៉ៅខោ។ គ. តា ⇨ ទៅវិហារ។ ឃ. កុមាររ៉ុំពូកែរាំ ⇨ ឆែយ៉ាំ។ ង. នារីខំញ៉ាំ ⇨ តៅស៊ូ។ **លំហាត់ទី4៖** ក. ម៉ូតូ ខ. តៅហ៊ូ គ. កូនង៉ា ឃ. ទ្រអ៊ូ ង. ប៉ាហ៊ី ច. អាយ៉ៃ

ជំពូកទី៤

ប្រកបនឹង ក ក់ ង ង់ ច ច់ ញ ញ់ ត ត់ ន ន់

រយៈពេល	48ម៉ោ
ចំណងជើងសមត្ថភាព	
មេរៀនទី១	ស្តាប់៖ រឿង ទន្សាយចង់ស៊ីចេក
មេរៀនទី២	អាននិងសរសេរ៖ ប្រកបនឹង ក ក់
មេរៀនទី៣	អាននិងសរសេរ៖ ប្រកបនឹង ង ង់
មេរៀនទី៤	អាននិងសរសេរ៖ ប្រកបនឹង ច ច់
មេរៀនទី៥	រៀនសាឡើងវិញ៖ ប្រកបនឹង ក ក់ ង ង់ ច ច់
មេរៀនទី៦	អាននិងសរសេរ៖ ប្រកបនឹង ញ ញ់
មេរៀនទី៧	អាននិងសរសេរ៖ ប្រកបនឹង ត ត់
មេរៀនទី៨	អាននិងសរសេរ៖ ប្រកបនឹង ន ន់
មេរៀនទី៩	រៀនសាឡើងវិញ៖ ប្រកបនឹង ញ ញ់ ត ត់ ន ន់
មេរៀនទី១០	អាននិងសរសេរ៖ ប្រកបនឹង ប ប់
មេរៀនទី១១	អាននិងសរសេរ៖ ប្រកបនឹង ម
មេរៀនទី១២	អាននិងសរសេរ៖ ប្រកបនឹង យ
មេរៀនទី១៣	រៀនសាឡើងវិញ៖ ប្រកបនឹង ប ប់ ម យ
មេរៀនទី១៤	អាននិងសរសេរ៖ ប្រកបនឹង ល ល់
មេរៀនទី១៥	អាននិងសរសេរ៖ ប្រកបនឹង វ
មេរៀនទី១៦	អាននិងសរសេរ៖ ប្រកបនឹង ស ស់
មេរៀនទី១៧	រៀនសាឡើងវិញ៖ ប្រកបនឹង ល ល់ វ ស ស់
មេរៀនទី១៨	ស្តាប់៖ រឿង ដឹងសងដឹង អំបែងសងអំបែង
មេរៀនទី១៩	អាននិងសរសេរ៖ ស្រៈពេញតួ៖ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

មេរៀនទី១	**ស្តាប់៖ រឿង ទន្សាយចង់ស៊ីចេក**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីលក្ខណៈល្អ និង លក្ខណៈអាក្រក់របស់តួអង្គបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី70ដល់ទំព័រទី71

	រូបភាព៖ ទំព័រទី 70 – 71
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ27
ណែលំហាត់	**លំហាត់ទី1៖** ក. 3 ខ. 1 គ. 2 ឃ. 5 ង. 4 ច. 6 **លំហាត់ទី2៖** ក. ចង់ស៊ីចេក ខ. សត្វបោកប្រាស់

មេរៀនទី២	**អាននិងសរសេរ៖ ប្រកបនឹង៖ ក ក់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹងក ក់ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី72 ដល់ទំព័រទី73 **រូបភាព៖** មួក ពូក ទូក គោក លលក កក់សក់ ដៃកចារ តុកកែ បរវរេ៖គោ អក្សរចល័ត **ប័ណ្ណពាក្យ៖** មួក ពូក ទូក គោក លលក កក់សក់ ដៃកចារ តុកកែ បរវរេ៖គោ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ក. តុកកែ ខ. ទូក គ. កុក ឃ. លលក ង. គោក ច. កក់សក់ **លំហាត់ទី2៖** មួក ចេក កាក កុក លលក **លំហាត់ទី3៖** ចៅចេកដឹកទឹកកក។ ចៅបូកក់សក់។ នារីបៈឈូក។

មេរៀនទី៣	**អាននិងសរសេរ៖ ប្រកបនឹង៖ ង ង់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ង ង់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី74 ដល់ទំព័រទី75 **រូបភាព៖** ពោង កំពង់ទឹក ទោង ដូង ទំពាំង ធុងទឹក បោៈឈូង ចុងដូង លាងពាងទឹក ហាងសាំង អក្សរចល័ត **ប័ណ្ណពាក្យ៖** ពោង កំពង់ទឹក ទោង ដូង ទំពាំង ធុងទឹក បោៈឈូង ចុងដូង លាងពាងទឹក ហាងសាំង...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** កំបាំង សំណង់ ទង់ជាតិ ទំពាំង ចំបើង ចងមុង រនាំង កំពង់ **លំហាត់ទី2៖** ក. ដូង , ខ. ធុង **លំហាត់ទី3៖** លេង លែង កំពង់ទឹក រោង ទងជាង ពែង ហាង តោង **លំហាត់ទី4៖** ដឹង ពោង កំពង់ទឹក

មេរៀនទី៤	**អាននិងសរសេរ៖ ប្រកបនឹង ៖ ច ច់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ច ច់ បានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី76 ដល់ទំព័រទី77 **រូបភាព៖** សំពោច បាច់ ទោច កាច់ រនោច ទោចតោងមែកឈើ អក្សរចល័ត **ប័ណ្ណពាក្យ៖** សំពោច បាច់ ទោច កាច់ រនោច ទោចតោងមែកឈើ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** លិច លួច សើច កាច់ **លំហាត់ទី2៖** ក. ទោច ខ. សំពោច

មេរៀនទី៥	**រៀនសាឡើងវិញ**
រយៈពេល	4ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ច ច់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី78ដល់ទំព័រទី79 **រូបភាព៖** ក្លួច កង់ កាច់ កង់ ពែងអក្សរចល័ត **ប័ណ្ណពាក្យ៖** ក្លួច កាច់ បាច ពែង ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ក. កង់ ខ. ពពក គ. បាក់ ឃ. រពឹង **លំហាត់ទី2៖** សេកចឹកចេកទុំ។ ចៅចេកញ៉ាំអំបុកជាមួយចេកទុំ។ សំណាងកំពុងដាំនោង។ **លំហាត់ទី3៖** រក តោង ធាក់ សក់ ថង់ កាក់ កក ទោង សង់ បាច **លំហាត់ទី4៖** ក. ទោចតោងមែកឈើ។ ខ. ពូទូចជាក់ជុចនៅបឹងខាងលិច។

មេរៀនទី៦	**អាននិងសរសេរ៖ ប្រកបនឹង ញ ញ់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ញ ញ់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី80 ដល់ទំព័រទី81 **រូបភាព៖** រុញ ទាញ បាញ់ ពេញ ទិញ ចេញ សំណាញ់ បង់សំណាញ់ អក្សរចល័ត **ប័ណ្ណពាក្យ៖** រុញ ទាញ បាញ់ ពេញ ទិញ ចេញ សំណាញ់ បង់សំណាញ់...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ក. ចេញលេង ខ. ទិញ គ. សំណាញ់ ឃ. រុញ **លំហាទី2៖** ក. ពូម៉ាញ់ដឹកទំនិញទៅផ្សារ។ ខ. នីតាទៅទិញផាមួង។

	គ. ចៅដួងលេងរុញឡាន។ **លំហាត់3៖** ក. ទំនិញ ខ. ជួញ គ. ពេញ

មេរៀនទី៧	**អាននិងសរសេរ៖ ប្រកបនឹង ត ត់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ត ត់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី82 ដល់ទំព័រទី83 **រូបភាព៖** បឹត កាត់ ពោត ទាត់ កាំបិត ជូត លោត ងូតទឹក សិតសក់ អក្សរចល័ត **ប័ណ្ណពាក្យ៖** បឹត កាត់ ពោត ទាត់ កាំបិត ជូត លោត ងូតទឹក សិតសក់...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** កាត់ គិត កំណាត់ កាំបិត បាត់បង់ ធាត់ ឆោត ចត នំបត់ ងូតទឹក ពោត កើត បៀត ចិត ផុត ងូត **លំហាត់ទី2៖** នំបត់ ធំធាត់ គាត់ **លំហាត់ទី3៖** ក. កាំបិត ខ. ងូតទឹក គ. លោត

មេរៀនទី៨	**អាននិងសរសេរ៖ ប្រកបនឹង ន ន់**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យប្រកបនឹង ន ន់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី84 ដល់ទំព័រទី85 **រូបភាព៖** រាំគែន ទឹកជំនន់ ថៃសួន ចាបចឹកចាន់ទុំ អានរឿងនិទាន អក្សរចល័ត **ប័ណ្ណពាក្យ៖** មៀន មាន់ ជើងពាន គែន ចាន សួន ទៀន រៀន ទឹកជំនន់ ជូន ជំនួន ប៉ាន់តែ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ក. ជើងពាន ខ. មៀន **លំហាត់ទី2៖** ជំនន់ មែនទែន ចំនួន មួយពាន់ ជឿនលឿន ជំនួន **លំហាត់ទី3៖** ក. មេមាន់ ខ. ជីដូន គ. បូផាន់ណា ឃ. ចៀន **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. នេះជាចានដែក។ ខ. សុជាតិដើរលេងនៅក្នុងសួនច្បារ។ គ. ពូមាចចិញ្ចឹមមេមាន់យកពងនិងសាច់។

មេរៀនទី៩	**រៀនសារឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យប្រកបនឹង ន ន់ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី86 ដល់ទំព័រទី87 **រូបភាព៖** លោតបាញ់រុញឡានកាត់សក់រាំគែនអក្សរចល័ត **ប័ណ្ណពាក្យ៖** មៀន មាន់ ជើងពាន គែន ចាន សួន ទៀន រៀន ទឹកជំនន់ ជួន ជំនួន ប៉ាន់តែ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** បន់ បត់ បាញ់ គន់ ចាញ់ មាត់ សំណាញ់ កាត់ ជន់ ពាន់ សាញ់ **លំហាត់ទី2៖** ក. ទាញ ខ. សំណាញ់ គ. កាត់សក់ ឃ. រាំគែន **លំហាត់ទី3៖** ក. រុញ ខ. បាញ់ គ. កាត់ ឃ. ពោត ង. ជួន ច. ចាន់ **លំហាត់ទី4៖** ក. ពូពេញកំពុងបង់សំណាញ់។ ខ. កុមារាកុមារីឈរលេងមុខថ្នាក់។ (ចម្លើយជាក់ស្តែង)

មេរៀនទី១០	**អាននិងសរសេរ៖ ប្រកបនឹង ប ប់**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ប ប់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី88 **រូបភាព៖** ចាប ចបកាប់ ដប ដប់ **ប័ណ្ណពាក្យ៖** ចាប ចបកាប់ ដប ដប់...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ចាប់ ដប់ រៀបរាប់ កំណប់ សំណាប **លំហាត់ទី2៖** ក. ម៉ែទៅដកសំណាប។ ខ. ពុកកាប់ដី។ គ. សំកើបសំរាម។

មេរៀនទី១១	**អាននិងសរសេរ៖ ប្រកមនឹង ម**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង មបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី89 ដល់ទំព័រទី90 **រូបភាព៖** សម ទទឹម មើម ចៀម នំគម សាមសិប សំរាម អក្សរចល័ត **ប័ណ្ណពាក្យ៖** សម ទទឹម មើម ចៀម នំគម សាមសិប សំរាម...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** សូម បូម ហាម ទទឹម ហើម ចៀម ឈាម ញញឹម រោម គោម នំគម

	លំហាត់ទី2៖ សិស្សចម្លងកន្សោមពាក្យនិងល្បះក្នុងសៀវភៅទំព័រ92 **លំហាត់ទី3៖** ក. មើម ខ. ញញឹម គ. គោម ឃ. សម **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. មៀមជាសត្វរកស៊ីពេលយប់។ ខ. ដំឡូងនេះមើមតូចតែវែង។

មេរៀនទី១២	**អាននិងសរសេរ៖ ប្រកបនឹង យ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី91 **រូបភាព៖** បាយ ផ្លែប្រពាយ ទីទុយ លុយ **ប័ណ្ណពាក្យ៖** បាយ ផ្លែប្រពាយ ទីទុយ លុយ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** កកាយ មួយ ងើយ រលួយ ទីទុយ **លំហាត់ទី2៖** ក. ទីទុយ ខ. ប្រពាយ គ. លុយ

មេរៀនទី១៣	**រៀនសាឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី92 ដល់ទំព័រទី93 **រូបភាព៖** ទីទុយ ប្រពាយ កើយ ឃាយ រោយ មួយរយរៀល កុមារដើរទៅសាលារៀន **ប័ណ្ណពាក្យ៖** ទីទុយ ប្រពាយ កើយ ឃាយ រោយ មួយរយរៀល កុមារដើរទៅសាលារៀន...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) រសើប ហើប មៀម ឃាយ ហើយ **លំហាត់ទី2៖** ក. ចៅចាន់ ⇨ ចាប់គោ។ ខ. ឃាយសំ ⇨ លីចបទៅចម្ការ។ គ. ផាន់យ៉ា ⇨ មុតដៃនឹងកាំបិតចេញឈាម។ ឃ. ម៉ែសុកី ⇨ ខំរាប់លុយ។ **លំហាត់ទី3៖** ក. រៀបរាប់ ខ. ចាបពួក គ. សើម ឃ. បាយ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. ចាបទុំលើមែកឈើ។

	ខ. ចៅដូចរាប់ពីមួយដល់ដប់ ។ គ. សត្វមៀមមានភ្នែកធំ។ ឃ. យាយចាន់ហូបស្លា

មេរៀនទី១៤	**អាននិងសរសេរ៖ ប្រកបនឹង ល ល់**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង ល ល់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី94ដល់ទំព័រទី95 **រូបភាព៖** អំពិល ដួល បបែល ហែល បាល់ ដល់ រំយោល រំដួល ក្មេងបីនាក់បបួលគ្នាទៅលេងបាល់ ក្មេងពីរនាក់លេងបាល់ដួល អក្សរចល័ត **ប័ណ្ណពាក្យ៖** អំពិល ដួល បបែល ហែល បាល់ ដល់ រំយោល រំដួល ក្មេងបីនាក់បបួលគ្នាទៅលេងបាល់ ក្មេងពីរនាក់លេងបាល់ដួល...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** រិល ពុល ដួល វាល់ មួល ដល់ បបែល ហែល ប្រដាល់ អំពិល អំបិល រំយោល **លំហាត់ទី2៖** ក. អំពិល ខ. ដួល គ. បបែល ឃ. បាល់ ង. អំបិល ច. លុយ **លំហាត់ទី3៖** ក. រំដួល ខ. ដល់ គ. រំយោល **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. ជីតាសីហាចូលចិត្តមើលប្រដាល់។ ខ. ត្រីបបែលហែលក្នុងសមុទ្រ។ គ. ផ្កាំរំយោលមានពណ៌ក្រហម។

មេរៀនទី១៥	**អាននិងសរសេរ៖ ប្រកបនឹង វ**
រយៈពេល	2ម៉
វត្ថុបំណង	អាន និង សរសេរពាក្យប្រកបនឹង វ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី96 ដល់ទំព័រទី97 **រូបភាព៖** ដាវ សាវម៉ាវ សៀវភៅ ឡើវអាវ កំសៀវ កែវ ងាវ អាវ អក្សរចល័ត **ប័ណ្ណពាក្យ៖** ដាវ សាវម៉ាវ សៀវភៅ ឡើវអាវ កំសៀវ កែវ ងាវ អាវ ជីតាសុខាដេញសាជ្រៀវពេលទំនេរសុខាអានសៀវភៅ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** អាវ ឡើវអាវ ឆេវឆាវ ចៃវ ងាវ សាវម៉ាវ **លំហាត់ទី2៖** ក. អាវ ខ. កែវ គ. កំសៀវ **លំហាត់ទី3៖**

	ក. ម្តាយសំដែរអាវ។ ខ. សុគីហែរបាយ។ គ. សុខាកំពុងអានសៀវភៅ។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) សានចូលចិត្តញុាំងាវឆា។ ធីតាទៅផ្សារទិញសាវម៉ាវ។ សុភាពក់អាវរងា។

មេរៀនទី១៦	**អាននិងសរសេរ៖ ប្រកបនឹង ស ស់**
រយៈពេល	2ម៉
វត្ថុបំណង	អាននិងសរសេរពាក្យប្រកបនឹង ស ស់ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី98 ដល់ទំព័រទី99 **រូបភាព៖** ឈើគូស រនាស់ ញាស់ អំបោស ជួសជុល ពស់ អក្សរចល័ត **ប័ណ្ណពាក្យ៖** ឈើគូស រនាស់ ញាស់ អំបោស ជួសជុល ពស់ ពូសួសលីរនាស់ទៅរាស់ដីចម្ការ សានងូតទឹកដុសសាប៊ូរាល់ពេល...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** វាស់ អស់ របួស ខុស ចាស់ លួស ញាស់ **លំហាត់ទី2៖** ក. ជួសជុល ខ. ឈើគូស **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. នារីបោសសម្អាតផ្ទះ។ ខ. តាសំរបួសដៃ។ គ. ពូឈុំជួសជុលរនាស់។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) 1. សុខាលីរនាស់។ 2. នារីទិញអំបោស។ 3. ខ្ញុំមានឈើគូសបីប្រអប់។

មេរៀនទី១៧	**រៀនសាឡើងវិញ**
រយៈពេល	4ម៉
វត្ថុបំណង	អាននិងសរសេរពាក្យប្រកបនឹង ស ស់ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី100 ដល់ទំព័រទី101 **រូបភាព៖** ដួល អំពិល បាល់ ឡេវ ដាវ រនាស់ ញាស់ អក្សរចល័ត **ប័ណ្ណពាក្យ៖** ឈើគូស រនាស់ ញាស់ អំបោស ពូសួសរាស់ដី ពស់វែក

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** វិល មូល ពុល អំពិល កល់ ដាល់ បាល់ សល់ រវល់ ញើស លួស ប្រាក់កាស ចំណាស់ រលាស់ **លំហាត់ទី2៖** ក ⇨ លើសពីប្រាំពាន់រៀល។ ខ ⇨ លេងបាល់។ គ ⇨ មានពណ៌ក្រហមទាំងអស់។ ឃ ⇨ ពាក់អាវពណ៌ខៀវ។ ង ⇨ មានពិស។ **លំហាត់ទី3៖** ក. កំសៀវ ខ. ឆេវឆាវ គ. ឡេវអាវ ឃ. សៀវភៅ ង. សេសសល់ ច. រាល់ពេល ឆ. បែកញើស ជ. រមាស់ ឈ. គាស់គល់ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) សុផលមកដល់សាលារៀននៅម៉ោងប្រាំមួយនិងសាមសិបនាទី។ ចៅសល់ចេះចាយតែក្រដាសមួយរយរៀលទេ។ **លំហាត់ទី5៖** (ចម្លើយជាក់ស្តែង) ចាន់ថាធ្វើការឡើងបែកញើស។ ម៉ាណាកើតរមាស់។ ម៉ាក់ពាក់អាវដៃវែង។

មេរៀនទី១៨	**ស្តាប់៖ រឿង ដឹងសងដឹង អំបែងសងអំបែង**
រយៈពេល	2ម៉
វត្ថុបំណង	សង្ខេបរឿងឡើងវិញតាមរយៈរូបភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី102 **រូបភាព៖** ផ្លែដឹងជាប់នឹងខ្នងប្រើស ឆ្កែខាំគ្នាធ្វើឱ្យបែកអំបែង
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ27
ឆ្លើយនឹងសំណួរ	1. បុរសខ្វីដឹងពីសេដ្ឋី 2. សេដ្ឋីមិនព្រមទទួលយករបស់ថ្មីទេ 3. សេដ្ឋីខ្វីអំបែងពីបុរស 4. បន្ទាប់ពីមហាក្សត្រកាត់ក្តីបុរសនិងសេដ្ឋីសុខចិត្ត
កំណែលំហាត់	**លំហាត់៖** សិស្សនិទានរឿង(ចម្លើយជាក់ស្តែង)

មេរៀនទី១៩	**អាននិងសរសេរ៖ ស្រៈពេញតួ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ**
រយៈពេល	4ម៉

វត្ថុបំណង	អាននិងសរសេរពាក្យស្រៈពេញតួបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី103 ដល់ទំព័រទី104 **រូបភាព៖** អគារ ឱសថ ឪម៉ាល់ ឫស ឪពុក ក្រឪឈូក នេះជាឫស្សីពីងពង់ អក្សរចល័ត **ប័ណ្ណពាក្យ៖** អគារ ឱសថ ឪម៉ាល់ ឫស ឪពុក ក្រឪឈូក នេះជាឫស្សីពីងពង់...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** ឥសី ឥឡូវ ឧសភា ឪពុក ឯណា ឱសថ ឱវាទ ឫកពា ឪឡឹក **លំហាត់ទី2៖** ក. ឪពុក ខ. ឧសភា គ. ឥឡូវ ឃ. ឪឡឹក ង. ឥសី ច.ឪម៉ាល់ ឆ. ឫកពា ជ. ឫស្សី **លំហាត់ទី3៖** ក. ឪឡឹក ខ. ក្រឪឈូក គ. ឫស ឃ. អគារ **លំហាត់ទី4៖** ក. ក្រឪឈូក ឯណា ខ. ឪពុក ឱសថ **លំហាត់ទី5៖** ក. សុផាយំព្រោះរឭកម្តាយ។ ខ. តើអ្នកចូលចិត្តញ៉ាំឪឡឹកដែរឬទេ? គ. តើថ្នាក់រៀនអ្នកនៅឯណា? **លំហាត់ទី6៖** (ចម្លើយជាក់ស្តែង) ក. ឪពុកខ្ញុំចូលចិត្តពិសាក្រឪឈូក។ ខ. តើផ្ទះឯងនៅឯណា? គ. ចេកណាំវ៉ាខ្ចីជាឱសថ។

ជំពូកទី៥

ព្យញ្ជនៈផ្ងើជើង

រយៈពេល	92ម៉
ចំណងជើងសមត្ថភាព	
មេរៀនទី១	អាននិងសរសេរៈ ព្យញ្ជនៈនិងជើងព្យញ្ជនៈ
មេរៀនទី២	អាននិងសរសេរៈ ក្ក ក្ឃ ក្រ ក្ល ក្ស ក្ក ក្ខ ក្ន ក្ម
មេរៀនទី៣	អាននិងសរសេរៈ ខ្ក ខ្ខ ខ្ឃ ខ្យ ខ្ល ខ្ស ខ្ស ខ្ន ខ្ម
មេរៀនទី៤	រៀនសាឡើងវិញៈ ក្ស ក្ល ក្ន ក្ម ខ្ល ខ្យ ខ្ន ខ្ម
មេរៀនទី៥	អាននិងសរសេរៈ គ្រ គ្ន គ្ម ឃ្ល ឃ្ម ឃ្ន ឃ្ម
មេរៀនទី៦	អាននិងសរសេរៈ ច្ប ច្រ ច្ន ឆ្ក ឆ្ត ឆ្ត ឆ្ត ឆ្ល ឆ្ម ឆ្ន ឆ្ស ឆ្ន ឆ្ម
មេរៀនទី៧	រៀនសាឡើងវិញៈ គ្រ គ្ន គ្ម ឃ្ល ឃ្ម ឃ្ន ឃ្ម ច្ប ច្រ ច្ន ឆ្ក ឆ្ត ឆ្ត ឆ្ត ឆ្ល ឆ្ម ឆ្ន ឆ្ស ឆ្ន ឆ្ម
មេរៀនទី៨	អាននិងសរសេរៈ ជ្រ ជ្ឈ ឈ្ស ឈ្ន ឈ្ម ឈ្ល
មេរៀនទី៩	វេយ្យាករណ៍ៈ សញ្ញាសួរ សញ្ញាខណ្ឌ និងសញ្ញាឧទាន (? ។ !)
មេរៀនទី១០	អាននិងសរសេរៈ ប្ត ប្រ ប្ល ប្ម
មេរៀនទី១១	អាននិងសរសេរៈ ផ្ក ផ្ត ផ្ឆ ផ្ឆ ផ្ត ផ្ន ផ្ន ផ្ល ផ្ស ផ្ន
មេរៀនទី១២	រៀនសាឡើងវិញៈ ប្ត ប្ល ប្ម ផ្ត ផ្ល ផ្ន
មេរៀនទី១៣	អាននិងសរសេរៈ ព្ន ព្រ ព្យ ភ្ញ ភ្ញ ភ្ន ភ្ល
មេរៀនទី១៤	អាននិងសរសេរៈ ម្ក ម្ខ ម្ច ម្ច ម្ត ម្ច ម្ច ម្ន ម្ព ម្ម ម្រ ម្ល ម្ស ម្ត ម្ព
មេរៀនទី១៥	រៀនសាឡើងវិញៈ ព្ន ព្រ ព្យ ភ្ញ ភ្ញ ភ្ន ភ្ល ម្ក ម្ខ ម្ច ម្ច ម្ត ម្ច ម្ច ម្ន ម្ព ម្ម ម្រ ម្ល ម្ស ម្ត ម្ព
មេរៀនទី១៦	អាននិងសរសេរៈ ត្ន ត្ម ត្ម ត្រ ត្ល ត្ព
មេរៀនទី១៧	អាននិងសរសេរៈ ឋ្ក ឋ្ត ឋ្ច ឋ្ច ឋ្ត ឋ្ម ឋ្ល ឋ្ច
មេរៀនទី១៨	រៀនសាឡើងវិញៈ ត្ន ត្ម ឋ្ច ឋ្ម
មេរៀនទី១៩	អាននិងសរសេរៈ ទ្រ ទ្ធ ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្ង
មេរៀនទី២០	អាននិងសរសេរៈ ល្ង ល្ង ល្ឃ ល្ត ល្ម ល្ង ល្ត ល្ម ហ្ល ហ្ង
មេរៀនទី២១	រៀនសាឡើងវិញៈ ទ្រ ទ្ធ ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្ង ល្ង ល្ង ល្ឃ ល្ត ល្ម ល្ង ល្ត ល្ម ហ្ល ហ្ង
មេរៀនទី២២	អាននិងសរសេរៈ ស្ក ស្ត ស្ង ស្ន ស្ម ស្ត ស្ល ស្ន ស្ម ស្ព ស្ត ស្ម ស្ល ស្រ ស្ង ស្ព
មេរៀនទី២៣	ស្តាប់ៈ រឿង ទន្សាយរត់ប្រណាំងជាមួយអណ្តើក
មេរៀនទី២៤	រៀនសាឡើងវិញៈ ព្យញ្ជនៈផ្ងើជើងដែលមានសូរដូចគ្នា

មេរៀនទី១	**អាននិងសរសេរ៖ ព្យញ្ជន:និងជើងព្យញ្ជន:**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរជើងព្យញ្ជន:ទាំង៣៣តួបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រទី106ដល់ទំព័រទី107 **រូបភាព៖** តារាងព្យញ្ជន: និងជើងព្យញ្ជន:
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ◌្ក ⇨ ក ◌្ ⇨ ច ◌្ ⇨ ធ ◌្ក ⇨ ត ◌្ ⇨ ទ **លំហាត់ទី2៖** ត្ត ថ្ថ ទ្ធ ធ្ន ន្ន យ្យ ប្រ ល្ល វ្ស ស្ស ហ្គ ឡ្ឋ អ្ន **លំហាត់ទី3៖** ណ្ណ ង្ង ន្ត

មេរៀនទី២	**អាននិងសរសេរ៖ ក្ក ក្ឋ ក្រ ក្ត ក្ស ក្ក ក្ង ក្ន ក្ម**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជន:ផ្ញើជើង ក្ត ក្ឋ ក្រ ក្ត ក្ស ក្ក ក្ង ក្ន ក្ម បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី108 ដល់ទំព័រទី109 **រូបភាព៖** ក្ងោក ក្ដម ក្អែក ក្តាន់ ក្តាម ក្បាល ក្បួន ក្ងាន របាំក្ងោក រទេះគោ **ប័ណ្ណពាក្យ៖** ក្ងោក ក្ដម ក្អែក ក្តាន់ ក្តាម ក្បាល ក្បួន ក្ងាន ឬរបាំក្ងោក រទេះគោ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក. របាំក្ងោក ខ. ក្អែក គ. ក្តាម ឃ. ក្បួន **លំហាត់ទី2៖** ក. ក្មេង ⇨ ក្មាង ខ. កូន ⇨ ក្ងោក គ. សត្វក្ងានធ្វើក ⇨ ក្ងិកក្ងក់ ឃ. ក្បឿង ⇨ ក្បាច់ **លំហាត់ទី3៖** ក. ក្តាន់ ខ. ក្ដម **លំហាត់ទី4៖** ក. ចេះ អ្នក ខ. សំ ក្បឿង គ. ក្តាន់

មេរៀនទី៣	**អាននិងសរសេរ៖ ខ្ញ ខ្ត ខ្ន ខ្ជ ខ្ត ខ្យ ខ្ល ខ្ញ ខ្យ ខ្ញ ខ្ន ខ្ម**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជន:ផ្ញើជើង ខ្ញ ខ្ត ខ្ន ខ្ជ ខ្ត ខ្យ ខ្ល ខ្ញ ខ្យ ខ្ញ ខ្ន ខ្ម បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី110 ដល់ទំព័រទី111 **រូបភាព៖** ខ្ទឹម ខ្នុះ ខ្លែង ខ្លា ខ្មើយ ខ្មុរ អាគារ **ប័ណ្ណពាក្យ៖** ខ្ទឹម ខ្នុះ ខ្លែង ខ្លា ខ្មើយ ខ្មុរ អាគារ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ខ្មើយ ខ្នុះខ្លាយ ខ្មៅ ខ្ពស់ ខ្លែង ខ្សែ ខ្ចី ខ្ទឹម ខ្ទី ខ្យល់ **លំហាត់ទី2៖** ក. ខ្នុះ ខ. ខ្ទឹម គ. ខ្យង

	លំហាត់ទី3៖ ក. ខ្ញុំ ខ្មែរ ខ. ខ្ញុំ ខ្លាច គ. ខ្ញុំ ខ្ពស់ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ខ្លាជាសត្វសាហាវ។ រដូវរំហើយឆៃយ៉ាលេងបង្ហោះខ្លែង។ មាលាគេងកើយខ្នើយ។

មេរៀនទី៤	**រៀនសាឡើងវិញ**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង ក្ស ក្ត ក្ន ក្ម ខ្ត ខ្ស ខ្ម ខ្ន ឱ្បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី112ដល់ទំព័រទី113 **រូបភាព៖** ខ្នុរ ក្មេង ខ្សង ខ្លា គ្រួសារមួយញ៉ាំបាយជុំគ្នា រូបក្មេងរៀនក្នុងថ្នាក់ **ប័ណ្ណពាក្យ៖** ខ្នុរ ក្មេង ខ្សង ខ្លា ក្សេមក្សាន្ត
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក្សេមក្សាន្ត ក្លិន ក្នុង ក្មេង ខ្លួន ខ្លែង ខ្សង ខ្នុរ ខ្នើយ ខ្មែរ ខ្មាញ់ ខ្មៅ ខ្សែ ខ្លាំង **លំហាត់ទី2៖** សិស្សអានល្បៃខាងក្រោម គ្រួសាររបស់នារីរស់នៅជួបជុំគ្នាយ៉ាងសុខក្សេមក្សាន្ត។ នៅក្រោយផ្ទះនារីមានចម្ការខ្នុរ។ **លំហាត់ទី3៖** ក. ខ្នុរ ខ. ខ្សង គ. ខ្លែង **លំហាត់ទី4៖** ក. ក្លិន ខ. ខ្លែង គ. ខ្មែរ **លំហាត់ទី5៖** ក. ក្មេងៗ ⇨ កំពុងលេងខ្លែង។ ខ. ក្នុងថ្នាក់រៀនសុភី ⇨ មានការរៀបចំស្អាតបាត។ គ. សត្វក្អែកស្រែកខ្លាំងៗ ⇨ នៅក្បែរភូមិ។ ឃ. សុភីរៀបចំមុងខ្នើយ ⇨ ក្រោយពេលក្រោកពីដំណេក។

មេរៀនទី៥	**អាននិងសរសេរៈ គ្រ គ្ន គ្ម ឃ្ល ឃ្ង ឃ្ន ឃ្ម**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាន និង សរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើងៈ គ្រ គ្ន គ្ម ឃ្ល ឃ្ង ឃ្ន ឃ្ម បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី114 ដល់ទំព័រទី115 **រូបភាព៖** ឃ្លោក ឃ្មាប ឃ្មោះ គ្រែ ឃ្មុំ ក្រូចឃ្វិច **ប័ណ្ណពាក្យ៖** ឃ្លោក ឃ្មាប ឃ្មោះ គ្រែ ឃ្មុំ ក្រូចឃ្វិច
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** គ្រាប់ គ្មាន ឃ្លោង ឃ្លាំង ឃ្វិច ឃ្មុំ ឃ្លាន គ្រូ

	លំហាត់ទី2៖ ក. ឃ្មោះ ខ. គ្រែ **លំហាត់ទី3៖** ក. ឃ្វាល ខ. ក្រូចឃ្វិច គ. អ្នកគ្រូ គ្រប់គ្នា **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ឃ្មុំហើរក្របលម្អងផ្កា។ បូណាគេងលើគ្រែពូក។

មេរៀនទី៦	**អាននិងសរសេរ៖ ច្ឋ ច្រ ច្ន ឆ្ក ឆ្ត ឆ្ន ឆ្ព ឆ្ល ឆ្ង ឆ្ត ឆ្ង ឆ្ន ឆ្ម**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង ច្ឋ ច្រ ច្ន ឆ្ក ឆ្ត ឆ្ន ឆ្ព ឆ្ល ឆ្ង ឆ្ត ឆ្ង ឆ្ន ឆ្ម បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី116 ដល់ទំព័រទី117 **រូបភាព៖** ច្បុក ច្រៀង ឆ្កែ ត្រីឆ្ពិន ត្រីឆ្កោក ឆ្នាំង ឆ្នឹង ឆ្មា **ប័ណ្ណពាក្យ៖** ច្បុក ច្រៀង ឆ្កែ ត្រីឆ្ពិន ត្រីឆ្កោក ឆ្នាំង ឆ្នឹង ឆ្មា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** សិស្សអានពាក្យនិងឈ្មោះក្នុងសៀវភៅទំព័រ 117 **លំហាត់ទី2៖** ឆ្លើយឆ្លង ឆ្នាំ ត្រីឆ្ពិន **លំហាត់ទី3៖** ក. ត្រីឆ្ពិន ខ.ឆ្នឹង **លំហាត់ទី4៖** ក. ឆ្វែល ខ. ច្រូត ឆ្លើយឆ្លង

មេរៀនទី៧	**រៀនសាឡើងវិញ**
រយៈពេល	6ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង៖ គ្រ គ្ន គ្ម ឃ្ល ឃ្ង ឃ្ម ឃ្ម ច្ឋ ច្រ ច្ន ឆ្ក ឆ្ត ឆ្ន ឆ្ព ឆ្ល ឆ្ង ឆ្ត ឆ្ង ឆ្ន ឆ្ម បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី118 ដល់ទំព័រទី119 **រូបភាព៖** ឃ្លោក គ្រែ ឃ្មុំ ឃ្មោះ ច្បុក ឆ្កែ ឆ្នឹង ឆ្នាំង ឆ្មា ក្មេងឃ្វាលគោ ច្រូតស្រូវ **ប័ណ្ណពាក្យ៖** ឃ្លោក គ្រែ ឃ្មុំ ឃ្មោះ ច្បុក ឆ្កែ ឆ្នឹង ឆ្នាំង ឆ្មា ក្មេងឃ្វាលគោ ច្រូតស្រូវ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក. ឃ្លោក ខ. ឃ្មោះ គ. ច្រូត ឃ. ឃ្មាប **លំហាត់ទី2៖** ក. គ្រែ ខ. ឆ្នាំង គ. ឆ្កែ ឃ. ឆ្មា **លំហាត់ទី3៖** នារីកើតឆ្នាំឆ្លូវ។ សានទៅឃ្វាលគោ។ កុមារលេងគ្រាប់ក្រួស។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ឆ្កែព្រុសដេញចោរ។ ឆ្មាដេញចាប់កណ្តុរ។

មេរៀនទី៨	**អាននិងសរសេរ៖ ជ្រ ជ្ឋ ឈ្ង ឈ្ន ឈ្ម ឈ្ល**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង ជ្រ ជ្ឋ ឈ្ង ឈ្ន ឈ្ម ឈ្ល បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី120 ដល់ទំព័ទី121 **រូបភាព៖** ជ្រឹង ឈ្លូស ឈ្នាង ជ្រូក ទឹកជ្រោះ ដំឡូងជ្វា ម្ហូបអាហារ **ប័ណ្ណពាក្យ៖** ជ្រឹង ឈ្លូស ឈ្នាង ជ្រូក ទឹកជ្រោះ ដំឡូងជ្វា ម្ហូបអាហារ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក. ឈ្លូស ខ. ឈ្នាង គ. ជ្រឹង ឃ. ជ្រូក **លំហាត់ទី2៖** ក. សត្វឈ្លូស ⇨ បោលចូលព្រៃ។ ខ. បូផាចិញ្ចឹម ⇨ ជ្រូកលក់។ គ. ឈ្នាង ⇨ គេប្រើសម្រាប់រកត្រី។ ឃ. ក្នុងបឹងនេះ ⇨ មានឈ្លើងច្រើនណាស់។ ង. ពេលរៀន ⇨ កុំឈ្លោកខ្លាំងពេក។ **លំហាត់ទី3៖** ក. នៅក្បែរមាត់ជ្រោះសម្បូរជ្រឹងណាស់។ ខ. ឈ្លូសជាសត្វរស់នៅក្នុងព្រៃ។ គ. ពូជ្រុញចាប់ជ្រូក។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ពូណាងជាក់ឈ្មោះកូនបានពិរោះ។ ជើមដំឡូងជ្វាវារពេញដី។

មេរៀនទី៩	**វេយ្យាករណ៍៖ សញ្ញាសួរ សញ្ញាខណ្ឌ និង សញ្ញាឧទាន** (?- ។ - !)
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់ សញ្ញាសួរ សញ្ញាឧទាន និងសញ្ញាខណ្ឌ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី122 ដល់ទំព័រទី123 **រូបភាព៖** ក្មេងពីរនាក់ មនុស្សជីកដី ក្មេងពីរនាក់អានសៀវភៅ ក្មេងស្រីសំពះ ក្មេងប្រុសអានសៀវភៅ សត្វស្វា ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ28
កំណែលំហាត់	**លំហាត់ទី1៖** ក. សញ្ញា ។ ខ. សញ្ញា ! សញ្ញា ។ គ. សញ្ញា ? ឃ. សញ្ញា ។ ង. សញ្ញា ! សញ្ញា។ **លំហាត់ទី2៖** តើឯងរៀនថ្នាក់ទីប៉ុន្មាន ? ខ្ញុំរៀនថ្នាក់ទី២។ យី! សម្លនេះឆ្ងាញ់ណាស់។ (ចម្លើយជាក់ស្តែង)

មេរៀនទី១០	**អាននិងសរសេរ៖ ប្ត ប្រ ប្ល ប្ព**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈផ្ញើជើង ប្ត ប្រ ប្ល ប្ព បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី124 ដល់ទំព័រទី125 **រូបភាព៖** ប្រាសាទ កំប្រុក ប្រើស ត្រីប្លាធូ ប្រឹក លេខប្រាំ **ប័ណ្ណពាក្យ៖** ប្រាសាទ កំប្រុក ប្រើស ត្រីប្លាធូ ប្រឹក លេខប្រាំ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ប្រទេស រំកើប ប្រាសាទ ប្អូន ប្រសើរ ប្រដៅ ប្រដេញ ប្រឹក ប្រើស **លំហាត់ទី2៖** ក. កុំរត់ប្រដេញ ⇨ គ្នាប្រយ័ត្នដួល។ ខ. ប្រាសាទអង្គរវត្ត ⇨ ជាសម្បត្តិវប្បធម៌របស់ខ្មែរយើង។ គ. សត្វប្រើស ⇨ រត់ប្រូចចូលព្រៃបាត់។ ឃ. ប្អូនៗត្រូវ ⇨ ប្រឹងប្រែងរៀនសូត្រ។ ង. ប្រទេសខ្មែរ ⇨ សម្បូរប្រាសាទបុរាណល្អៗ។ **លំហាត់ទី3៖** ក. បងប្អូន សៀមរាប ខ. ប្រទេស ប្រាសាទ គ. ប្រាសាទ គង់វង្ស **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) នៅសមុទ្រសម្បូរត្រីប្លាធូ។ កំប្រុកនៅលើចុងដូង។ ប្រឹកហើរសំកាំងលើវាលស្រែ។ សត្វប្រើសបោលប្រូចចូលក្នុងព្រៃ។

មេរៀនទី១១	**អាននិងសរសេរ៖ ផ្ត ផ្ត ផ្ង ផ្ង ផ្ត ផ្ន ផ្ន ផ្ស ផ្ស ផ្ន**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈផ្ញើជើង ផ្ត ផ្ត ផ្ង ផ្ង ផ្ត ផ្ន ផ្ន ផ្ស ផ្ស ផ្ន បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី 126 ដល់ទំព័រទី127 **រូបភាព៖** ផ្តៅ ផ្តិល ផ្នះ ផ្សិត ផ្សោត ផ្តៅ **ប័ណ្ណពាក្យ៖** ផ្តៅ ផ្តិល ផ្នះ ផ្សិត ផ្សោត ផ្តៅ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក. ផ្តៅ ខ. ផ្សោត គ. ផ្តិល **លំហាត់ទី2៖** ក. ផ្សិត ខ. ផ្សោត **លំហាត់ទី3៖** ក. ប្រទេសខ្មែរសម្បូរផ្តៅ។ ខ. សុកីទិញផ្តៅកុលាប។

	គ. នៅខេត្តក្រចេះមានសត្វផ្សោត។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ពូព្រីងទើបសង់ផ្ទះថ្មី។ តាសានយកផ្តៅធ្វើជាសាឡុង។ យាយនិលទិញផ្តិលប្រាក់។

មេរៀនទី១២	**រៀនសារឡើងវិញ**
រយៈពេល	2ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង ប្ត ប្ល ប្ន ផ្ត ផ្ល ផ្ន បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី 128ដល់ទំព័រទី 129 **រូបភាព៖** ប្តូរវត្ថុគ្នា ផ្តា ផ្តិល ផ្សិត ផ្សោត បងប្អូន **ប័ណ្ណពាក្យ៖** ប្តូរវត្ថុគ្នា បងប្អូន ផ្តិល ផ្សិត ផ្សោត ផ្តា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ប្តី ប្តឹង ប្តូរ ប្លែក ប្លន់ ប្អូន ផ្តៅ ផ្តេក ផ្លែ ផ្លូវ ផ្អាប់ ផ្តើល ផ្អែម **លំហាត់ទី2៖** ក. ផ្លូវ ខ. បងប្អូន គ. ផ្តិល ឃ. ផ្តៅ **លំហាត់ទី3៖** ក. ពូប្រាជ្ញ ⇨ នាំប្រពន្ធទៅលេងប្រាសាទអង្គរវត្ត ។ ខ. សុខចេះ ⇨ មើលថែប្អូន។ គ. ពូសំលីរនាស់ ⇨ ដើរតាមផ្លូវ។ ឃ. ផ្លែខ្នុរនេះ ⇨ មានរសជាតិផ្អែមឆ្ងាញ់។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ទឹកអំពៅមានរសជាតិផ្អែម។ ចាន់ណាចូលចិត្តពាក់អាវផ្តា។ ផ្លូវទៅកាន់ប្រាសាទអង្គរមានដើមឈើខ្ពស់ៗ។

មេរៀនទី១៣	**អាននិងសរសេរ ឮ ព្រ ព្យ ភ្ញ ភ្ល ភ្ន ភ្ត**
រយៈពេល	4ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈធ្វើដើង ឮ ព្រ ព្យ ភ្ញ ភ្ល ភ្ន ភ្ត បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី 130 ដល់ទំព័រទី 131 **រូបភាព៖** ផ្លែព្នៅ ព្រៃ ព្យុះ ភ្លួរ ភ្នែក ភ្នំ ភ្លុក ភ្លៀង **ប័ណ្ណពាក្យ៖** ផ្លែព្នៅ ព្រៃ ព្យុះ ភ្លួរ ភ្នែក ភ្នំ ភ្លុក ភ្លៀង
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
កំណែលំហាត់	**លំហាត់ទី1៖** ក. ភ្ញៀវ ខ. ព្នៅ គ. ភ្នែក

	លំហាត់ទី2៖ ញៅ ព្រឺព្រួច ព្រួល ព្រលឹម ភ្ញាក់ ភ្ញុំ ភ្ញុក ភ្នែក ភ្លៀង **លំហាត់ទី3៖** ព្រឹកនេះសុកីទៅផ្សារ។ ដើមឆ្នាំនេះមានភ្លៀងច្រើន។ ដំរីមានភ្លុកពណ៌ស។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ពូឌីភ្ជួរស្រែ។ គ្រួសារបូណាទៅលេងភ្នំជីសូរ។

មេរៀនទី១៤	**អាននិងសរសេរ៖ ម្ត ម្ន ម្ម ម្ប ម្ព ម្ជ ម្ឆ ម្ន ម្ត ម្ប ម្ព ម្ភ ម្ម ម្យ ម្រ ម្ល ម្ស ម្ហ ម្អ**
រយៈពេល	6ម៉ោ
វត្ថុបំណង	អាននិងសរសេរពាក្យផ្សំពីព្យញ្ជនៈផ្ញើជើង ៖ ម្ត ម្ន ម្ម ម្ប ម្ព ម្ជ ម្ឆ ម្ន ម្ត ម្ប ម្ព ម្ភ ម្ម ម្យ ម្រ ម្ល ម្ស ម្ហ ម្អ បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី132 ដល់ទំព័រទី133 **រូបភាព៖** ម្តាក់ ម្នេស ម្នាស់ លេខ២០ ម្រេច ម្តាយឱ្យកូនផឹកទឹក ធ្វើម្ហូប **បំណ្ណពាក្យ៖** ម្តាក់ ម្នេស ម្នាស់ លេខ២០ ម្រេច ម្ហូប ម្រុំ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
